# ព្រះពោធិសត្វ

## ភាគទី ២



## ព្រះសុវណ្ណសាម


រៀបរៀងដោយ
[illegible]
[illegible] ប៊ុត សាវង្ស

# សុវណ្ណសាមជាតក

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុមួយអង្គ ដែលជាអ្នកចិញ្ចឹមមាតាបិតា ត្រាស់នូវព្រះធម៌ទេសនានេះថា **កោ នុ មំ ឧសុនា វិជ្ឈិ** ដូច្នេះជាដើម ។

ដូចបានស្តាប់មក ក្នុងក្រុងសាវត្ថី មានកុលបុត្រម្នាក់ ជាបុត្រតែមួយក្នុងត្រកូលសេដ្ឋី ដែលមានសម្បត្តិ ១៨ កោដិ ។ កុលបុត្រនោះ ជាទីស្រឡាញ់ ជាទីចម្រើនចិត្តនៃមាតាបិតាដ៏ក្រៃលែង ។ ថ្ងៃមួយ កុលបុត្រនោះឯងកំពុងនៅលើប្រាសាទ បានបើកសីហបញ្ជរ សម្លឹងមើលមកថ្នល់ធំ ឃើញពួកមហាជនកាន់ផ្កាកម្រង និងគ្រឿងក្រអូបជាដើម ទៅកាន់ព្រះជេតពនមហាវិហារ ដើម្បីនឹងជួបជុំគ្នាស្តាប់នូវព្រះធម៌ទេសនា ទើបគិតថា សូម្បីយើង



ក៏ត្រូវទៅនឹងគេដែរ ។ កាលគិតដូច្នោះហើយ ទើបបានចាត់ចែងនូវផ្កាកម្រង និងគ្រឿងក្រអូប នាំយកទៅកាន់ព្រះវិហារ ប្រកបដោយសទ្ធា ថ្វាយសំពត់ ភេសជ្ជៈ និងទឹកជាដើម ដល់ព្រះសង្ឃ ហើយបូជាដល់អង្គព្រះដ៏មាន-ព្រះភាគ ដោយផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ថ្វាយបង្គំរួចក៏អង្គុយស្តាប់ព្រះធម៌ក្នុងទីដ៏សមគួរ ។

កាលដែលកុលបុត្រនោះ បានស្តាប់ព្រះធម៌ទេសនាហើយ ក៏បានឃើញទោសក្នុងកាមទាំងឡាយ និងបានកំណត់អានិសង្សនៃបព្វជ្ជា ។ លុះដល់បរិស័ទគ្រប់គ្នាត្រឡប់ទៅវិញអស់ហើយ ទើបថ្វាយបង្គំព្រះដ៏មានព្រះ-ភាគ ទូលសូមបព្វជ្ជា ។ អង្គសម្តេចព្រះភគវា ព្រះអង្គទ្រង់ត្រាស់ដល់កុលបុត្រនោះ យ៉ាងនេះថា ៖ ព្រះតថាគតទាំង-ឡាយ មិនញុំាងបុត្រដែលមាតាបិតាមិនទាន់បានអនុញ្ញាតឱ្យបព្វជ្ជានោះឡើយ ។ កុលបុត្រនោះ កាលដែលបានស្តាប់នូវព្រះពុទ្ធដីកាដូច្នោះហើយ ទើបថ្វាយបង្គំព្រះដ៏-មានព្រះភាគ ក្រាបទូលលាត្រឡប់មកគេហដ្ឋានវិញ ដល់

ហើយក៏បានក្រាបសំពះមាតាបិតាដោយសេចក្តីគោរព រួចបានពោលយ៉ាងនេះថា : បពិត្រ លោកឪពុកអ្នកម្តាយ កូននឹងបួសក្នុងសំណាក់នៃព្រះតថាគត ។

លំដាប់នោះ មាតាបិតារបស់កុលបុត្រនោះ បានស្តាប់ពាក្យរបស់កូនហើយ ក៏មានសភាពដូចជាបែកបេះ-ដូងជា ៧ ចម្រៀក ព្រោះមានបុត្រតែមួយ ញាប់ញ័រដោយសេចក្តីស្នេហាចំពោះបុត្រ បានពោលយ៉ាងនេះថា : កូនសម្លាញ់ កូនជាទំពាំងនៃត្រកូល ហាក់ដូចជាកែវភ្នែក ឬដូចជាជីវិតរបស់យើងទាំងពីរនាក់ ។ ឪពុកនិងម៉ែ បើវៀរចាកកូនហើយ នឹងមានជីវិតបានដូចម្តេចទៅ ជីវិតរបស់យើងទាំងពីរក៏ចាស់ណាស់ទៅហើយ នឹងស្លាប់ក្នុងថ្ងៃនេះថ្ងៃស្អែក ឬក៏ខានស្អែក យ៉ាងនេះ កូននៅប្រាថ្នាចាកចោលឪពុកម្តាយទៅទៀតឬ ។ ធម្មតាបព្វជ្ជាគឺបុគ្គលធ្វើបានដោយលំបាកក្រៃលែង កាលត្រូវការត្រជាក់ ក៏រមែងបានក្តៅ កាលត្រូវការក្តៅ ក៏រមែងបានត្រជាក់ ព្រោះហេតុនោះ កូនកុំបួសឡើយ ។



កុលបុត្រ បានស្តាប់ពាក្យរបស់មាតាបិតាដូច្នោះហើយ ក៏ដល់នូវទុក្ខទោមនស្ស អង្គុយឱនមុខ សៅសោក មិនបរិភោគអាហារអស់ ៧ ថ្ងៃ ។ លំដាប់នោះ មាតាបិតារបស់កុលបុត្រនោះ បានគិតគ្នាយ៉ាងនេះថា បើកូនរបស់យើងមិនបាននូវសេចក្តីអនុញ្ញាតឱ្យបួសទេ មុខតែនឹងស្លាប់ជាមិនខាន ហើយយើងនឹងមិនបានឃើញកូនទៀតឡើយ តែបើកូនយើងបានរស់នៅក្នុងភេទជាអ្នកបួស យើងគង់នឹងបានជួបប្រទះឃើញមុខតទៅទៀត ។ កាលដែលបានគិតគ្នាយ៉ាងនេះហើយ ទើបអនុញ្ញាតថា : នែកូនសម្លាញ់ មាតាបិតាអនុញ្ញាតឱ្យកូនហើយ ចូរកូនបួសចុះ ។

កុលបុត្រ បានស្តាប់ដូច្នោះ ក៏មានចិត្តត្រេកអរ បង្អោនសរីរៈទាំងអស់ចុះ ក្រាបទៀបបាទានៃមាតាបិតា ថ្វាយបង្គំលា ចេញពីក្រុងសាវត្ថី ទៅកាន់ជេតពនមហា-វិហារ ។ ទៅដល់ហើយ បានក្រាបថ្វាយបង្គំអង្គសម្តេចព្រះភគវា ទូលសូមបព្វជ្ជានឹងព្រះអង្គ ។ ព្រះបរមសាស្តាបានត្រាស់បង្គាប់ឱ្យភិក្ខុមួយអង្គ បំបួសកុលបុត្រនោះជា

សាមណេរ ។ ចាប់តាំងអំពីសាមណេរនោះបួសហើយ លាភសក្ការៈបានកើតឡើងយ៉ាងច្រើនដល់លោក ។ សាមណេរនោះបានញុំាងអាចារ្យនិងឧបជ្ឈាយ៍ឱ្យត្រេកអរ លុះដល់គ្រប់ព្រះជន្មហើយ ក៏បានឧបសម្បទាជាភិក្ខុ សិក្សាព្រះធម៌ព្រះវិន័យបាន ៥ វស្សាក៏គិតថា យើងនៅក្នុងទីនេះច្របូកច្របល់ទៅដោយពួកញាតិជាដើម មិនសមគួរដល់យើងឡើយ ។ ព្រះភិក្ខុ ប្រាថ្នានឹងបំពេញនូវវិបស្សនាធុរៈ ទើបរៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ហើយចេញអំពីជេតពនមហាវិហារ ទៅកាន់បច្ចន្តគ្រាម បានអាស្រ័យនៅនឹងសេនាសនៈក្នុងព្រៃ នាបច្ចន្តគ្រាមនោះឯង ។

ព្រះភិក្ខុអង្គនោះ ចម្រើនវិបស្សនាក្នុងទីនោះ សូម្បីព្យាយាមដល់ទៅ ១២ ឆ្នាំ ក៏មិនអាចញុំាងនូវគុណវិសេសឱ្យកើតឡើងបានឡើយ ។ ចំណែកមាតាបិតារបស់ព្រះភិក្ខុវិញ ពេលវេលាបានកន្លងទៅៗ ពួកជនទាំងឡាយដែលជាអ្នកធ្វើស្រែ ឬជាអ្នកជួញដូរឱ្យលោកសេដ្ឋីនោះ បាន



កាន់យកនូវសម្បត្តិនោះៗ ជារបស់ខ្លួន តាមដែលខ្លួនពេញចិត្ត សូម្បីទាសកម្មករក្នុងផ្ទះជាដើម ក៏កាន់យកមាសប្រាក់ និងរបស់របរផ្សេងៗ រត់ចេញពីផ្ទះអស់ទៅ ។ ក្រោយមក ជនទាំងពីរនាក់ក៏ធ្លាក់ខ្លួន ដល់នូវសេចក្ដីទុក្ខលំបាកពេញបន្ទុក មិនមានអ្នកទំនុកបម្រុងសូម្បីតែម្នាក់ឡើយ ត្រូវលក់ផ្ទះ ហើយក៏មិនមានទីអាស្រ័យនៅ ដល់នូវភាពជាបុគ្គលដែលគួរឱ្យអាណិតដ៏ក្រៃលែង ។ ជនទាំងពីរត្រូវស្លៀកដណ្ដប់សំពត់ចាស់ៗ កាន់អំបែងដើរសូមទានទីនេះ ទីនោះ ហើយអាស្រ័យនៅក្រោមដើមឈើ ឬក៏សំយាបផ្ទះនៃអ្នកដទៃ ។

ក្នុងកាលនោះ មានព្រះភិក្ខុមួយអង្គចេញចាកពីវត្តជេតពនមហាវិហារ ទៅដល់ទីនៅនាបច្ចន្តគ្រាម ចូលទៅក្នុងព្រៃ ដែលជាលំនៅនៃព្រះភិក្ខុបុត្ររបស់សេដ្ឋីអនាថានោះឯង ។ ព្រះភិក្ខុសេដ្ឋីបុត្របាន ធ្វើនូវអាគន្តុកវត្ត ដល់ព្រះភិក្ខុថ្មីនោះ និងគង់អង្គុយនៅជាសុខហើយ ទើបសួរថា : លោកដ៏មានអាយុ និមន្តមកពីណា ? ព្រះភិក្ខុ

អាគន្តុកៈក៏បានឆ្លើយថា : ខ្ញុំព្រះករុណា មកអំពីព្រះជេត-
ពនមហាវិហារ ។ ព្រះភិក្ខុសេដ្ឋីបុត្រ ក៏បានសន្ទនាសួរដល់
ការគង់នៅជាសុខនៃព្រះបរមសាស្តា និងព្រះមហាសាវ័ក
ជាដើម រួចហើយក៏បានសួរដល់មាតាបិតារបស់ខ្លួនថា :
លោកដ៏មានអាយុ ត្រកូលសេដ្ឋីឈ្មោះនោះ ក្នុងក្រុង
សាវត្ថីសុខសប្បាយទេឬ ? ព្រះភិក្ខុអាគន្តុកៈ តបថា :
អាវុសោ លោកកុំសួរនាំដល់ត្រកូលនោះឡើយ ។ ព្រះភិក្ខុ
សេដ្ឋីបុត្រសួរបញ្ជាក់ថា : តើយ៉ាងដូចម្តេចហ្នឹង លោកដ៏
មានអាយុ ? ព្រះភិក្ខុអាគន្តុកៈ ក៏បានឆ្លើយរៀបរាប់ថា :
ត្រកូលនោះ ខ្ញុំព្រះករុណា បានឮមកថា មានកូនប្រុសតែ
មួយ ហើយកូននោះក៏បានចេញបួសក្នុងព្រះពុទ្ធសាសនា
ចាប់តាំងតែពីកូនចេញបួសបាត់ទៅកាលណា ត្រកូលនោះ
ក៏មានការធ្លាក់ចុះ វិនាសហិនហោចនូវទ្រព្យសម្បត្តិជាបន្ត
បន្ទាប់ ឥឡូវនេះ សេដ្ឋីទាំងពីរនោះ ជាមនុស្សអត់ទ្រព្យ
កំព្រីកំព្រាគួរឱ្យអាណិតក្រៃលែង ។ គាត់ទាំងពីរកាន់
អំបែងដើរសូមទាន អាស្រ័យនៅតាមសំយាបផ្ទះរបស់



អ្នកដទៃ ។ ព្រះភិក្ខុសេដ្ឋីបុត្របានស្តាប់ពាក្យនៃព្រះភិក្ខុ
អាគន្តុកៈហើយ ក៏មិនអាចនឹងទប់ចិត្តបាន ទឹកភ្នែកស្រក់
មកជោកព្រះភក្ត្រ យំញ័រញាក់អស់ទាំងខ្លួនក្នុងពេលនោះ
ឯង ។ ព្រះភិក្ខុអាគន្តុកៈ ឃើញដូច្នោះហើយ ទើបសួរថា :
អាវុសោ ម៉េចបានជាលោកយំ ? ព្រះភិក្ខុសេដ្ឋីបុត្រ តប
ដោយអណ្តឺតអណ្តកថា : លោកដ៏មានអាយុ អ្នកទាំងពីរ
នោះជាមាតាបិតារបស់ខ្ញុំព្រះករុណា ខ្ញុំព្រះករុណាជាបុត្រ
របស់លោកទាំងពីរនោះ ។ ព្រះភិក្ខុអាគន្តុកៈ ក៏បានពោល
ថា : មាតាបិតារបស់អាវុសោ ដល់នូវសេចក្តីវិនាសព្រោះ
អាស្រ័យដោយអាវុសោហ្នឹងហើយ ចូរអាវុសោទៅបដិបត្តិ
មាតាបិតានោះទៅ ។ ព្រះភិក្ខុសេដ្ឋីបុត្រ គិតថា អាត្មាអញ
សូម្បីព្យាយាមដល់ទៅ ១២ ឆ្នាំ ក៏មិនអាចសម្រេចបាននូវ
មគ្គផលអ្វីឡើយ គឺយើងជាបុគ្គលអភ័ព្វ ប្រយោជន៍អ្វីដោយ
ទ្រព្យគឺបព្វជ្ជានេះ អាត្មាអញនឹងសឹកទៅជាគ្រហស្ថ ចិញ្ចឹម
មាតាបិតា ឱ្យទាន ដូច្នេះនឹងជាបុគ្គលមានសុគតិភព
ប្រព្រឹត្តទៅក្នុងជាតិខាងមុខបានដែរ ។ គិតដូច្នេះហើយ

ក៏បានប្រគល់កន្លែងនៅក្នុងព្រៃនោះ ដល់ព្រះភិក្ខុអាគន្តុកៈ នមស្ការព្រះភិក្ខុអាគន្តុកៈ ដែលលោកជាព្រះថេរៈហើយ ស្អែកឡើងទើបចេញអំពីព្រៃ ទៅដោយលំដាប់តាមមាគ៌ា រហូតដល់វិហារខាងក្រោយព្រះជេតពន មិនឆ្ងាយពីក្រុងសាវត្ថី ។ កន្លែងត្រង់នោះ មានផ្លូវបែកជាពីរ ផ្លូវមួយទៅទីក្រុងសាវត្ថី ឯផ្លូវមួយទៀតដទៃទៅកាន់ព្រះជេតពន-មហាវិហារ ។ ព្រះភិក្ខុឈប់ហើយរេរានៅទីត្រង់នោះ គិតថា យើងនឹងទៅរកមាតាបិតាមុន ឬក៏ទៅគាល់ព្រះ-ទសពលជាមុនហ្ន៎ ហើយគិតតទៅទៀតថា យើងមិនបានជួបមាតាបិតាយូរណាស់ហើយ ក៏ពិតមែន តែចាប់តាំងពីនេះទៅ យើងនឹងគាល់ព្រះពុទ្ធជាអម្ចាស់បានដោយលំបាក ថ្ងៃនេះ យើងនឹងគាល់ព្រះសម្មាសម្ពុទ្ធបរមសាស្តា ហើយស្តាប់ព្រះធម៌ទេសនាសិន ស្អែកឡើងសឹមទៅរកមាតាបិតាពីព្រលឹម ។ គិតដូច្នេះហើយ ក៏លះបង់ផ្លូវទៅក្រុងសាវត្ថី ព្រោះមានឧបនិស្ស័យល្អជាគ្នា ទើបចូលកាន់មាគ៌ាទៅកាន់មហាវិហារព្រះជេតពន ក៏បានដល់មហា-



វិហារក្នុងវេលាល្ងាច ។

ក្នុងថ្ងៃនោះឯង ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ទ្រង់ត្រួតមើលឧបនិស្ស័យនៃសត្វ ក្នុងវេលាជិតភ្លឺ ទ្រង់ទតឃើញឧបនិស្ស័យនៃព្រះភិក្ខុអង្គនោះ ទើបព្រះអង្គទ្រង់ត្រាស់ពណ៌នាគុណនៃមាតាបិតា ដោយមាតុបោសកសូត្រ ក្នុងពេលដែលព្រះភិក្ខុនោះនិមន្តមកដល់ ។ ក៏ព្រះភិក្ខុអង្គនោះ ឈរនៅខាងក្រោយបំផុតនៃបរិស័ទ ស្តាប់ព្រះធម្ម-កថាដ៏ពីរោះ ទើបរំពឹងថា អាត្មាអញបានគិតទុកថានឹងទៅជាគ្រហស្ថ ទើបអាចបដិបត្តិបម្រុងបម្រើមាតាបិតាបាន ប៉ុន្តែព្រះសាស្តាទ្រង់ត្រាស់ថា សូម្បីជាបព្វជិតក៏ធ្វើនូវឧបការៈដល់មាតាបិតាបានដែរ ។ បើយើងមិនបានមកគាល់ព្រះសាស្តាជាមុនទេនោះ យើងនឹងបាត់បង់នូវបព្វជ្ជាដែលមានសភាពបែបនេះជាពុំខាន ។ ឥឡូវនេះ យើងមិនត្រូវសឹកទៅជាគ្រហស្ថឡើយ គឺនៅជាបព្វជិតបែបនេះឯង ហើយនឹងទំនុកបម្រុងមាតាបិតាតទៅ ។

ព្រះភិក្ខុអង្គនោះ បានក្រាបថ្វាយបង្គំព្រះបរម-

សាស្តា ។ ព្រលឹមឡើង បានចូលទៅកាន់រោងស្លាក ទទួលភត្តាហារនិងយាគូ ដែលបានដោយស្លាក ។ ជាភិក្ខុនៅព្រៃ ១២ ឆ្នាំបានដល់នូវភាពដូចជាអ្នកបរាជ័យហើយ។ ព្រះភិក្ខុចេញអំពីព្រះជេតពន ចូលទៅកាន់ក្រុងសាវត្ថី គិតថា យើងនឹងទទួលយាគូមុន ឬក៏ទៅរកមាតាបិតាមុនហ្ន៎ ហើយក៏បានសម្រេចចិត្តថា ទៅទទួលយាគូសិន ព្រោះការមានដៃទទេចូលទៅរកមនុស្សកំព្រា ជាការពុំសមគួរឡើយ ។ ព្រះភិក្ខុ ទើបកាន់យកនូវយាគូនិមន្តទៅឈរនៅខ្លោងទ្វារផ្ទះចាស់ របស់មាតាបិតា បានឃើញមាតាបិតាដើរសូមបបរយាគូ ហើយចូលទៅអាស្រ័យនឹងសំយាបផ្ទះរបស់អ្នកដទៃ អង្គុយនៅទីនោះ ដល់នូវភាពជាមនុស្សកំព្រានិងលំបាកតោកយ៉ាកដ៏ក្រៃលែង ។ ព្រះភិក្ខុក៏មានសេចក្តីសោកកើតឡើង មានទឹកភ្នែកហូរ ឈរនៅក្នុងទីជិតៗនោះឯង ។ មាតាបិតា សូម្បីបានឃើញលោកកូនហើយ ក៏ចាំមិនបាន ។ មាតារបស់ព្រះភិក្ខុនោះសំគាល់ថាភិក្ខុនោះឈរដើម្បីបិណ្ឌបាត ទើបបានពោលថា បពិត្រ



លោកម្ចាស់អើយ ចង្ហាន់បិណ្ឌបាត ឬក៏អ្វីៗដែលគួរទំពាឆាន់ ដែលនឹងគួរប្រគេនចំពោះលោកម្ចាស់នោះ ខ្ញុំព្រះ-ករុណាមិនមានទេ សូមនិមន្តទៅខាងមុខទៀតចុះ ។ ព្រះ-ភិក្ខុបានស្តាប់ពាក្យរបស់មាតា ក៏បន្ថែមសេចក្តីសោកយ៉ាងខ្លាំងក្លា ទឹកនេត្រាជោកព្រះភ័ក្ត្រ ដើមកអួលអាក់និយាយមិនរួច ក្តុកក្តួលក្នុងចិត្តដ៏ក្រៃលែង ។ សូម្បីមាតាពោលដូច្នោះពីរដង បីដង ក៏នៅឈរធ្មឹងដដែលក្នុងទីនោះឯង ។

លំដាប់នោះ បិតារបស់ព្រះភិក្ខុ បាននិយាយនឹងភរិយាថា : ទៅមើលឱ្យជិតមើល៍ ជាបុត្ររបស់យើងទេដឹង ។ មាតារបស់ព្រះភិក្ខុ ក្រោកឡើងហើយដើរទៅជិតសម្លឹងមើល ក៏ចាំបាន ។ មាតាទន់ជើងអង្គុយចុះយំស្រែកពេញទំហឹង ឱនក្រាបទៅជិតបាទារបស់ព្រះភិក្ខុដែលជាបុត្របង្កើតរបស់ខ្លួន បរិទេវនាការញ័រអស់ទាំងកាយដូចគេអង្រួន ។ ចំណែកបិតា ក៏ស្រែកយំដើរទៅទីជិតព្រះភិក្ខុជាកូនរបស់ខ្លួនដែរ គួរឱ្យស្រណោះដ៏ក្រៃលែង ។ ចំណែកព្រះភិក្ខុនោះ ឃើញមាតានិងបិតា

ដូច្នេះ ក៏មិនអាចនឹងទប់កាយបាន ក៏យំចេញសំឡេងមកក្រៅហ៊ូៗ មួយភ្លែតក្រោយមក ទើបព្រះភិក្ខុខំទប់សេចក្តីសោក ហើយពោលថា : ញោមទាំងពីរកុំគិតអ្វីឡើយ អាត្មានឹងចិញ្ចឹមញោមឱ្យជាសុខសម្រាន្ត ។ ព្រះភិក្ខុបានញុំាងមាតាបិតាឱ្យកក់ក្តៅក្នុងចិត្តហើយ បានជូននូវយាគូដល់ញោមទាំងពីរ និងឱ្យគាត់អង្គុយក្នុងទីដ៏សមគួរមួយ ហើយបាននិមន្តទៅបិណ្ឌបាត នាំភិក្ខាហារមកជូនគាត់ឱ្យបរិភោគទៀត កាលដែលសួរដឹងថា គាត់ពិសាឆ្អែតហើយ ទើបនិមន្តរកចង្ហាន់ដើម្បីខ្លួនឯង ។ ព្រះភិក្ខុ បានរកទីកន្លែងដ៏សមគួរជូនឱ្យមាតាបិតាអាស្រ័យនៅ ហើយបានបដិបត្តិ ទំនុកបម្រុងនូវញោមទាំងពីរ ដោយយកចិត្តទុកដាក់ជាទីបំផុត សូម្បីភត្តដែលកើតឡើងក្នុងបក្ខគឺបក្ខភត្តជាដើម ដែលខ្លួនបានមក ក៏ជូនដល់មាតាបិតា ។ ខ្លួនឯងនិមន្តបិណ្ឌបាត បានមកក៏ឆាន់ មិនបានទេក៏អត់ ។ បានសំពត់ចាំវស្សាក៏ដោយ សំពត់យ៉ាងណាមួយដែលជាអតិរេកលាភក៏ដោយ ក៏ជូនដល់មាតាបិតា ហើយបោកគក់



ជ្រលក់សំពត់ចាស់ៗ ដែលញោមទាំងពីរស្លៀកដណ្តប់ហើយ ដេរប៉ះសម្រាប់ប្រើប្រាស់ស្លៀកដណ្តប់ខ្លួនឯង ។ ថ្ងៃដែលព្រះភិក្ខុអង្គនោះបានចង្ហាន់ឆាន់ មានតិចថ្ងៃណាស់ ថ្ងៃដែលមិនបានមានច្រើនជាង ឯចំណែកសំពត់ស្លៀកសំពត់ដណ្តប់ ដែលជាចីវររបស់លោកសៅហ្មងពេញទី ។ កាលព្រះភិក្ខុបដិបត្តិចិញ្ចឹមមាតាបិតារហូតមក ក៏មានរូបកាយស្គមស្គាំង ទាំងសម្បុរក៏សៅហ្មង ឯឆ្អឹងជំនីររគីមរគាម រវីមរវាមទៅដោយសរសៃ ទាំងសាច់លឿងស្លាំងទៀតផង ។

ព្រះភិក្ខុសង្ឃទាំងឡាយ ដែលជាសព្រហ្មចារីនឹងព្រះភិក្ខុជាអ្នកចិញ្ចឹមមាតាបិតានោះ បានឃើញនូវព្រះភិក្ខុនោះស្គាំងស្គមដូច្នេះ ទើបសួរថា : អាវុសោ កាលមុនសរីរវណ្ណៈរបស់លោកស្រស់បស់ណាស់ ប៉ុន្តែឥឡូវនេះមានសភាពស្លេកស្លាំងស្គាំងស្គម សៅហ្មងមិនស្រស់បស់ឡើងលឿង ហើយសរសៃរវាមពេញខ្លួន តើព្យាធិកើតឡើងដល់អាវុសោឬ ? ព្រះភិក្ខុបានឆ្លើយតបថា : លោក

ដ៏មានអាយុទាំងឡាយ ខ្ញុំព្រះករុណាមិនមានព្យាធិអ្វីទេ តែមានធុរៈត្រូវចិញ្ចឹមមាតាបិតា ហើយបានរៀបរាប់សេចក្តីទាំងអស់ប្រាប់ដល់សព្រហ្មចារីភិក្ខុទាំងឡាយនោះ ។ ភិក្ខុទាំងឡាយនោះឯង ទើបពោលថា : អាវុសោ ព្រះសាស្តាមិនប្រទានអនុញ្ញាត ក្នុងការញុាំងរបស់ដែលគេប្រគេនដោយសទ្ធាឱ្យធ្លាក់ចុះនោះទេ ក៏អាវុសោកាន់យករបស់ដែលគេឱ្យដោយសទ្ធា ទៅឱ្យដល់ពួកគ្រហស្ថ ជាការធ្វើកិច្ចមិនសមគួរឡើយ ។ ព្រះភិក្ខុដែលជាអ្នកចិញ្ចឹមមាតាបិតានោះ បានស្តាប់ពាក្យរបស់ព្រះភិក្ខុទាំងឡាយនោះហើយ ក៏មានការអៀនខ្មាស ហើយក៏បានលះបង់នូវការទំនុកបម្រុងមាតាបិតារបស់ខ្លួនទៀតផង ។ ព្រះភិក្ខុទាំងឡាយ នៅមិនទាន់ពេញចិត្តដោយហេតុមានប្រមាណប៉ុណ្ណេះ ទើបនាំគ្នាទៅគាល់ព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា : បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះនោះបានញុាំងរបស់ដែលគេឱ្យដោយសទ្ធាឱ្យធ្លាក់ចុះ ដោយការចិញ្ចឹមគ្រហស្ថ ។ ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ទ្រង់



ត្រាស់ហៅនូវព្រះភិក្ខុអង្គនោះមកត្រាស់សួរថា : នែភិក្ខុបានឮថា អ្នកកាន់យកនូវវត្ថុដែលគេឱ្យដោយសទ្ធា ទៅចិញ្ចឹមគ្រហស្ថពិតមែនឬ ? ព្រះភិក្ខុក៏តបថា : បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ។ ព្រះដ៏មានព្រះភាគ មានព្រះបំណងនឹងសរសើរការប្រព្រឹត្តរបស់ព្រះភិក្ខុនោះ និងព្រះអង្គទ្រង់ព្រះបំណង ដើម្បីនឹងប្រកាសនូវបុព្វចរិយារបស់ព្រះអង្គ ទើបព្រះអង្គទ្រង់ត្រាស់សួរបន្តទៀតថា : នែភិក្ខុ កាលដែលអ្នកចិញ្ចឹមនូវពួកគ្រហស្ថនោះ តើចិញ្ចឹមនូវពួកគ្រហស្ថណា ? ព្រះភិក្ខុបានក្រាបទូលថា : បពិត្រព្រះអង្គដ៏ចម្រើន គ្រហស្ថទាំងនោះ គឺជាមាតាបិតារបស់ខ្ញុំព្រះអង្គ ។ ដើម្បីនឹងញុាំងឧស្សាហៈឱ្យកើតឡើងដល់ព្រះភិក្ខុអង្គនោះ ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ព្រះអង្គបានប្រទាននូវសាធុការបីដងថា : សាធុ ! សាធុ ! សាធុ ! ហើយព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកតាំងនៅក្នុងផ្លូវដែលតថាគតដើរហើយ ព្រោះថា សូម្បីបុព្វចរិយារបស់តថាគតក៏បានទំនុកបម្រុង ចិញ្ចឹមមាតាបិតារបស់ខ្លួនដែរ។

ព្រះភិក្ខុដែលចិញ្ចឹមមាតាបិតានោះ បែរត្រឡប់ជាបាននូវការរីករាយចិត្តដ៏ក្រៃលែង ។ លំដាប់នោះ ព្រះភិក្ខុទាំង-ឡាយក៏បានក្រាបទូលអារាធនាសូមព្រះភគវាទ្រង់ប្រកាសនូវព្រះបុព្វចរិយា ទើបព្រះបរមសាស្តាដ៏ទ្រង់ញាណនាំនូវអតីតនិទានមកសម្តែងដូចតទៅនេះ :

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល នៅទីដែលមិនឆ្ងាយពីក្រុងពារាណសី មានភូមិរបស់នាយព្រានមួយ ឋិតនៅត្រើយអាយនៃទន្លេគង្គា និងមានភូមិរបស់នាយព្រានមួយទៀត ដែលតាំងនៅត្រើយខាងនាយនៃទន្លេនោះឯង។ ក្នុងភូមិទាំងពីរនោះ ភូមិមួយៗ មានប្រមាណជា ៥០០ ត្រកូល នាយនេសាទដែលជាធំពីរនាក់នៃភូមិទាំងពីរនោះ ជាសម្លាញ់នឹងគ្នា តាំងតែពីគ្រាដែលនៅក្មេងៗ ។ គេទាំងពីរនាក់បានសន្យានឹងគ្នាយ៉ាងនេះថា បើម្ខាងមានធីតា ហើយម្ខាងទៀតមានបុត្រ យើងនឹងធ្វើនូវអាវាហវិវាហ-មង្គលដល់បុត្រធីតាទាំងនោះ ។ លំដាប់នោះ ក្នុងផ្ទះរបស់នាយនេសាទ ដែលជាធំក្នុងភូមិត្រើយអាយ ក៏បាន



ប្រសូតបុត្រសមតាមប្រាថ្នា មាតាបិតាដាក់ឈ្មោះឱ្យថា **ទុកូលកុមារ** ព្រោះកុមារនោះ គឺពួកញាតិទាំងឡាយទទួលដោយទុកូលពស្ត្រ ក្នុងខណៈដែលប្រសូតនោះឯង ។ ចំណែកក្នុងផ្ទះរបស់នាយនេសាទដែលជាធំក្នុងភូមិត្រើយនាយ ក៏បានប្រសូតធីតា ត្រូវនឹងសន្យា មាតាបិតាបានឱ្យឈ្មោះថា **បារិកាកុមារី** ព្រោះនាងស្រីប្រសូតនៅត្រើយនាយ ។ កុមារនិងកុមារី គឺក្មេងប្រុសស្រីទាំងពីរ មានរូបស្អាតស្រស់ឆោមឆវី គួរជាទីគយគន់ សម្បុរកាយពណ៌មាសវិសេសលន់ពន់ប្រមាណ សូម្បីកើតក្នុងត្រកូលនាយព្រាន ក៏មិនបានធ្វើបាណាតិបាតឡើយ ។

ក្នុងកាលក្រោយមក ពេលដែលទុកូលកុមារមានអាយុបាន ១៦ ឆ្នាំ មាតាបិតាក៏បានពោលថា នឹងនាំបារិកា-កុមារីមកដើម្បីកូន ។ ដោយទុកូលកុមារ ចុតិមកអំពីព្រហ្មលោក ជាសត្វបរិសុទ្ធស្អាតបវរពិត ទើបបិទត្រចៀកទាំងពីរពោលថា : បពិត្រមាតាបិតា កូនមិនត្រូវការនៅគ្រប់គ្រងផ្ទះ សូមលោកទាំងពីរអនុគ្រោះ កុំពោលដូច្នេះ

បុត្រមិនត្រូវការឡើយ ។ ទោះបីមាតាបិតាមានវាចាពីរបីដង ក៏ទុកូលកុមារមិនប្រាថ្នាដដែល ។ ចំណែកបារិកាកុមារីស្រីស្រស់សោភា ក៏ដូចគ្នាដែរ កាលដែលមាតាបិតាពោលថា : នែកូនស្រី បុត្រនៃសម្លាញ់របស់មាតាបិតាឯណោះ គេមានរូបស្រស់គួរជ្រះថ្លា ស័ក្តិសមនឹងកូនស្រី គួរនាបីដូចជាដុំមាសទាំងទ្វេ មាតាបិតានឹងលើកកូនឱ្យទៅគេ បានជាគូគ្រង សមតាមបំណងដែលបានប៉ងទុក ។ នាងបារិកាក៏បានពោលហាមឃាត់ ហើយបិទត្រចៀកទាំងពីរ ព្រោះនាងទើបតែចុតិមកអំពីព្រហ្មលោក ជាសត្វបរិសុទ្ធ ។

ក្នុងគ្រានោះ ទុកូលកុមារបានបញ្ជូនដំណឹងសម្ងាត់ទៅដល់នាងបារិកាថា : បើបារិកាមានសេចក្តីត្រូវការដោយមេថុនធម្ម ក៏ចូរទៅកាន់ផ្ទះនៃបុគ្គលដទៃចុះ ខ្ញុំមិនមានការពេញចិត្តក្នុងមេថុនធម្មឡើយ ។ ចំណែកនាងបារិកាក្នុងចិត្តស្អាតថ្លា មិនប្រាថ្នាមេថុនធម្មដូចគ្នាដែរ ក៏បានបញ្ជូនដំណឹងសម្ងាត់ទៅដល់ទុកូលកុមារ ដែលមានសេចក្តីដូចគ្នា ។ ទោះជាអ្នកទាំងពីរមិនប្រាថ្នា ក៏មាតាបិតា



បានធ្វើអាវាហវិវាហមង្គលឱ្យ ដល់កូនប្រុសស្រី ដែលធ្លាប់មានឧបនិស្ស័យជាប្តីប្រពន្ធនឹងគ្នា ក្នុងសង្សារវដ្តមកដែរ ប៉ុន្តែជាតិនេះ គេទាំងពីរ មិនបានធ្លាក់ចុះកាន់សមុទ្រគឺកិលេសឡើយ គឺគេនៅជាមួយគ្នាដូចជាមហាព្រហ្ម ដូច្នោះឯង ។

ទុកូលបណ្ឌិតមិនសម្លាប់ត្រីឬសត្វដទៃឡើយ សូម្បីតែសាច់ដែលបុគ្គលនាំមក ក៏មិនលក់ដូរអ្វីទាំងអស់ ។ លំដាប់នោះ មាតាបិតាបានសន្ទនាជាមួយនឹងកូនថា : នែកូន កូនកើតមកក្នុងត្រកូលនាយព្រាន មិនប្រាថ្នានៅគ្រប់គ្រងផ្ទះ មិនធ្វើការសម្លាប់សត្វ តើកូននឹងធ្វើអ្វីទៅ ? ទុកូលបណ្ឌិត ឆ្លើយតបយ៉ាងនេះថា : បពិត្រមាតាបិតា បើអ្នកមានគុណទាំងពីរអនុញ្ញាត កូនទាំងពីរនឹងចេញទៅបួស ។ មាតាបិតា បានស្តាប់ដូច្នោះ ទើបអនុញ្ញាតថា : បើដូច្នោះ ចូរកូនទាំងពីរចេញទៅបួសចុះ ។ ទុកូលបណ្ឌិតនិងនាងបារិកាដ៏ឆ្លាតវៃ មានសេចក្តីរីករាយត្រេកអរ ក្រាបសំពះមាតាបិតា ហើយចេញអំពីផ្ទះ ទៅកាន់ហិមវន្ត-

ប្រទេសតាមដងទន្លេគង្គា សំដៅត្រង់ទៅស្ទឹងមិគសម្មតា ដែលហូរមកអំពីភ្នំហិមពាន្ត ចាក់ចូលទៅទន្លេគង្គានោះឯង ។

ខណៈនោះ ពិភពនៃសក្កទេវរាជ សម្តែងនូវអាការក្តៅឡើង សក្កទេវរាជទ្រង់អាវជ្ជនាការត្រួតត្រាពិចារណាមើល ក៏បានជ្រាបនូវការណ៍នោះ ទើបទ្រង់ត្រាស់ហៅព្រះវិស្សុកម្មទេវបុត្រមក ហើយត្រាស់ថា : នែម្នាលវិស្សុកម្មទេវបុត្រ មហាបុរសរ័ត្នទាំងពីរអង្គានាំគ្នាចេញចាកផ្ទះ ប្រាថ្នានឹងបួសប្រព្រឹត្តតបៈជាឫសី បានចូលទៅកាន់ព្រៃ នាហិមវន្តប្រទេស ព្រោះហេតុដូច្នោះ គួរឱ្យលោកទាំងពីរនោះ បានទីនៅអាស្រ័យផង ។ អ្នកចូរនិម្មិតនូវបណ្ណសាលា ព្រមទាំងបព្វជិតបរិក្ខារ ដើម្បីលោកទាំងពីរនោះ ក្នុងទីចាប់អំពីសម្មតានទីមក ឱ្យមានបរិវេណដ៏សមរម្យ ។ ព្រះវិស្សុកម្មទេវបុត្រ បានទទួលនូវព្រះទេវ-រាជបញ្ជាហើយ បានចាត់ចែងនូវកិច្ចការទាំងពួង រួចរាល់ស្រេចបាច់ និងបានដេញពួកម្រឹគទាំងពួកបក្សី ដែលមាន



សំឡេងមិនជាទីពេញចិត្ត ឱ្យគេចចេញអស់ទៅ ព្រមទាំងនិម្មិតផ្លូវដែលត្រូវចូលទៅកាន់បរិវេណនៃអាស្រមបទផង រួចហើយ ទើបវិលទៅកាន់ទីឋានរបស់ព្រះអង្គវិញ ។ ទុកូលបណ្ឌិតនិងនាងបារិកា បានឃើញផ្លូវដ៏សមរម្យកាលណា កាលណោះ ក៏យាត្រាទៅតាមផ្លូវនោះ រហូតដល់អាស្រមបទ ។ ទុកូលបណ្ឌិតបានចូលទៅកាន់បណ្ណសាលា ឃើញបព្វជិតបរិក្ខារ ក៏ជ្រាបច្បាស់ថា សក្កទេវរាជប្រទានដល់យើង ។ ទុកូលបណ្ឌិត ទើបបានដោះនូវសំពត់សាដកចេញ ហើយស្លៀកសំពត់សំបកឈើពណ៌ក្រហមមួយផ្ទាំងដណ្តប់មួយផ្ទាំង ទើបដាក់ស្បែកខ្លាលើស្មា ចងមណ្ឌលជដា ទ្រង់ភេទជាតាបស ហើយឱ្យនាងបារិកាបួសជាតបស្សិនី ។ ទាំងពីរអង្គាចម្រើនមេត្តាភាវនាក្នុងព្រៃ បួសជាតាបសតាបសី មិនមានអ្វីសៅហ្មងឡើយ ។ ដោយមេត្តានុភាពថ្នាក់កាមាវចរភូមិរបស់បព្វជិតទាំងពីរ ម្រឹគីម្រឹគា ទាំងបក្សាបក្សីក្នុងព្រៃទាំងពួង ត្រឡប់ជាមានមេត្តាចិត្តដល់គ្នា មិនមានសត្វណាបៀតបៀនដល់សត្វណា

ឡើយ ។ បារិកាតបស្សិនីនៅពេលបច្ចូសសម័យ ក៏បានរៀបចំទឹកនិងរបស់សម្រាប់ឆាន់ទុកស្រេចហើយ បោសសម្អាតអាស្រមបទ ព្រមទាំងកិច្ចទាំងពួង ។ ដល់វេលាគ្រាបុព្វណ្ហសម័យ តាបសតាបសី មិនមានអ្វីជាការខ្វាយ-ខ្វល់ បាននាំយកផលាផលមកឆាន់ ហើយចូលកាន់បណ្ណ-សាលា រៀងៗខ្លួន ចម្រើនសមណធម៌ សម្រេចការនៅក្នុងទីនោះៗឯង ។

វេលាកន្លងទៅត្រូវនឹងធម៌មិនទៀង សក្កទេវរាជស្ដេចយាងមកកាន់ទីទំនុកបម្រុងនៃព្រះមុនីទាំងពីរនោះ ។ ថ្ងៃមួយព្រះអង្គទ្រង់រំពឹងពិចារណា ឃើញការអន្តរាយនៃព្រះមុនីទាំងពីរអង្គនោះថា នេត្រានឹងងងឹតពិតពុំខាន ។ សក្កទេវរាជ ស្ដេចចុះចាកពីឋានទេវលោក ចូលទៅរកទុកូលបណ្ឌិត នមស្ការហើយទ្រង់ស្ថិតនៅក្នុងទីសមគួរមួយ រួចហើយព្រះអង្គទ្រង់ត្រាស់ប្រកាសដូច្នេះថា : បពិត្រ អ្នកស្វែងរកនូវគុណដ៏ចម្រើនអើយ អន្តរាយនឹងប្រាកដដល់លោកទាំងពីរ ដូច្នេះគួរតែលោកទាំងពីរមាន



បុត្រទុកសម្រាប់បដិបត្តិតទៅ គឺសូមលោកទាំងពីរសេពនូវលោកធម៌ ។ ទុកូលបណ្ឌិត បានស្ដាប់ពាក្យរបស់សក្ក-ទេវរាជយ៉ាងនេះហើយ ទើបពោលថា : បពិត្រសក្កទេវ-រាជ ព្រះអង្គត្រាស់អ្វីហ្នឹង អាត្មាទាំងពីរសូម្បីនៅកណ្ដាលផ្ទះ ក៏មិនបានសេពនូវលោកធម៌ឡើយ គឺយើងទាំងពីរលះនូវលោកធម៌នេះដោយខ្ពើមរអើម ដូចជាការខ្ពើមរអើមនូវគំនរលាមកដែលពេញទៅដោយដង្កូវ ក៏ឥឡូវយើងទាំងពីរចូលមកបួស នឹងធ្វើនូវកម្មដូច្នោះបានយ៉ាងដូចម្ដេចទៅ ។ សក្កទេវរាជទ្រង់ត្រាស់ថា : បពិត្រ ឥសីដ៏ចម្រើនអើយ លោកមិនចាំបាច់ធ្វើយ៉ាងនោះឡើយ លោកគ្រាន់តែយកដៃទៅស្ទាបអង្អែលពោះបារិកាតបស្សិនីប៉ុណ្ណោះ ក្នុងវេលាដែលនាងនោះមានរដូវ អត់មានត្រូវធ្វើអ្វីទៀតទេ ។ ទុកូលបណ្ឌិតទទួលថា : មហាបពិត្រ បើត្រឹមតែប៉ុណ្ណេះ អាត្មានេះអាចធ្វើបាន ។ សក្កទេវរាជនមស្ការទុកូលតាបសហើយ ទើបវិលវិញថ្កាន ត្រឡប់ទៅឋានរបស់ព្រះអង្គ ។ ចំណែកទុកូលបណ្ឌិត ក៏បានប្រាប់

ការពិតដល់ចារិកា ឱ្យនាងដឹងខ្លួនជាមុន លុះដល់វេលានាងមានរដូវកាលណា ទើបយកហត្ថាទៅស្ទាបអង្អែលត្រង់ផ្ទៃរបស់នាងតបស្សិនី ក្នុងកាលនោះឯង ។

ក្នុងគ្រានោះ ព្រះពោធិសត្វក៏ចុតិចាកទេវលោកមកបដិសន្ធិក្នុងផ្ទៃនៃនាងចារិកា លុះវេលាកន្លងទៅបាន ១០ មាសា នាងក៏ប្រសូតបុត្រមានសម្បុរល្អលុះបីដូចជាមាស ដោយហេតុនោះឯង មាតាបិតាទើបតាំងឈ្មោះឱ្យបុត្រថា **សុវណ្ណសាមកុមារ** ។ ក្នុងវេលាដែលចារិកាតបស្សិនីចូលព្រៃដើម្បីរកមូលផលាផល នាងកិន្នរីទាំងឡាយ ដែលឋិតនៅខាងក្នុងព្រៃភ្នំ បានមកប្រជុំគ្នាធ្វើនាទីជាមេដោះរីករាយសប្បាយរួមរស់ជាមួយនឹងសុវណ្ណសាមកុមារ ។ តាបសតាបសីទាំងពីរ បានស្រង់វារីឱ្យដល់ព្រះពោធិសត្វហើយ ក៏ដាក់ឱ្យផ្ទំនាបរមសាលា ក្នុងខណៈនោះ នាងកិន្នរីទាំងឡាយ នាំគ្នាសប្បាយ បីសុវណ្ណសាមកុមារទៅស្រង់ទឹកនៅនាចន្លោះភ្នំជាដើម ហើយឡើងកាន់កំពូលភ្នំប្រជុំទៅដោយផ្កា បានប្រដាប់ឱ្យសុវណ្ណសាមកុមារទៅ



ដោយបុប្ផជាតិផ្សេងៗ ហើយប្រោះព្រំផាត់លាបលើកាយដោយហរិតាលមនោសិលា និងបន្តក់មួយគ្រាប់ឱ្យជាប់នៅនាកណ្តាលថ្ងាស ហើយក៏បាននាំយកមកដាក់នៅលើសេយ្យាសន៍ក្នុងបណ្ណសាលា ។ ចំណែកនាងចារិកាត្រឡប់មកឱ្យបុត្របៅដោះ ក្នុងសភាពបែបនេះរហូតដល់ព្រះ-ពោធិសត្វបានធំ ។ មាតាបិតាគ្រប់គ្រងរក្សាបុត្រនោះ លុះរហូតដល់សុវណ្ណសាមកុមារចម្រើនវ័យវឌ្ឍនាការបាន ១៦ ឆ្នាំ ។ សុវណ្ណសាមនៅក្នុងបណ្ណសាលា មាតាបិតានាំគ្នាចូលព្រៃរកមូលផលាផល ។ លំដាប់នោះ ព្រះមហាសត្វទ្រង់គិតថា អន្តរាយអ្វីណានឹងគប្បីកើតមាន ដល់មាតាបិតារបស់យើងក្នុងកាលខ្លះ ទើបបានសង្កេតមើលផ្លូវនោះដែលមាតាបិតាដើរទៅ ។

ក្រោយមកថ្ងៃមួយ កាលដែលតាបសតាបសី នៅក្នុងព្រៃរកមូលផលាផល រហូតដល់ពេលល្ងាចត្រឡប់មកវិញ ដល់ទីជិតអាស្រមបទ មហាមេឃក៏បានតាំងឡើងភ្លៀងយ៉ាងខ្លាំងក៏បានធ្លាក់ចុះមក លោកទាំងពីរបានចូល

ទៅកាន់គល់ឈើមួយ ឈរនៅពីលើដំបូក ។ អាសិរពិស នៅខាងក្នុងដំបូកនោះ ត្រូវទឹកភ្លៀងលាយដោយក្លិនញើស ចាកសរីរៈនៃអ្នកទាំងពីរ ហូរចូលក្នុងរន្ធច្រមុះ ។ អាសិរ-ពិសមានសេចក្តីក្រោធ បានបញ្ចេញខ្យល់ ពីរន្ធច្រមុះ មកត្រូវចក្ខុទាំងពីររបស់តាបសតាបសីនោះ ។ ទាំងពីរអង្គ ក៏ងងឹតភ្នែកទាំងអស់មិនអាចមើលឃើញគ្នាបាន ។ ទុកូលបណ្ឌិត ហៅនាងបារិកាប្រាប់ថា : បារិកា ចក្ខុទាំងពីររបស់យើងងងឹតហើយ យើងមិនអាចមើលនាងឃើញទេ ។ ចំណែកនាងបារិកា ក៏ពោលយ៉ាងនោះដូចគ្នាដែរ ។ ទាំងពីរអង្គក្នុងវេលាដែលមើលគ្នានិងមើលផ្លូវមិនឃើញ ក៏បានឈរយំសោករៀបរាប់ ដោយយល់ថាឥឡូវនេះ ជីវិតយើងទាំងពីរនឹងមិនមានតទៅទៀតឡើយ។

តាបសនិងតបស្សិនីទាំងពីរអង្គនោះ មានបុព្វកម្មយ៉ាងណា ។ បានឮថា ក្នុងជាតិមុនអ្នកទាំងពីរកើតក្នុងត្រកូលពេទ្យ គ្រាមួយ ពេទ្យនោះរក្សារោគក្នុងភ្នែករបស់បុរសអ្នកមានទ្រព្យច្រើនម្នាក់ ។ បុរសនោះមានភ្នែកបាន



ផុតចាករោគហើយ មិនឱ្យទ្រព្យដែលជាតម្លៃនៃការរក្សាដល់លោកគ្រូពេទ្យ ។ លោកគ្រូពេទ្យនោះ មានសេចក្តីក្រោធ ទៅដល់ផ្ទះបានប្រាប់សេចក្តីនោះដល់ភរិយារបស់ខ្លួនថា ខ្ញុំរក្សារោគក្នុងភ្នែកឱ្យដល់បុរសនោះ បានជាសះស្បើយហើយ ប៉ុន្តែឥឡូវនេះគេមិនបានឱ្យទ្រព្យជាតម្លៃនៃការរក្សាដល់យើង តើយើងនឹងធ្វើយ៉ាងដូចម្តេចទើបល្អ ? ភរិយាបានស្តាប់ហើយក៏ខឹងក្រោធ ទើបពោលថា : យើងមិនត្រូវការទ្រព្យរបស់វានោះឡើយ អ្នកចូរផ្សំថ្នាំឱ្យវាបន្តក់ដាក់ឱ្យវាខ្វាក់ទាំងពីរតែម្តងទៅ ។ ស្វាមីក៏យល់ស្របតាមយ៉ាងនោះ ទើបចេញពីផ្ទះ ទៅរកបុរសនោះ ហើយបានធ្វើដូច្នោះឯង ។ បុរសអ្នកមានទ្រព្យច្រើននោះ មិនយូរប៉ុន្មាន ភ្នែកទាំងពីរ ក៏ត្រឡប់ទៅជាងងឹតវិញ ។ តាបសនិងតបស្សិនី បានសាងនូវបាបកម្មនេះទុកមក ទើបបានជាឥឡូវត្រូវងងឹតភ្នែកទាំងអស់គ្នា ដោយបាបកម្មនោះឯង ។

លំដាប់នោះ ព្រះពោធិសត្វគិតថា មាតាបិតារបស់យើង ក្នុងថ្ងៃដទៃៗ ធ្លាប់តែត្រឡប់មកក្នុងវេលាល្ងាច

ឥឡូវនេះហួសពេលដូច្នេះ យើងមិនដឹងរឿងអ្វីសោះ ។ ព្រះពោធិសត្វបានចេញទៅរកអ្នកទាំងពីរ ទៅតាមទិស ដែលបានកំណត់ទុក ហើយក៏ស្រែកហៅជាបណ្តើរៗ ។ មាតាបិតារបស់ព្រះពោធិសត្វ ស្តាប់ឮហើយចាំសំឡេង បុត្រក៏បានឆ្លើយតប ហើយពោលហាមដោយសេចក្តី ស្រឡាញ់ក្នុងបុត្រថា : កូនសម្លាញ់ ទីនេះមានអន្តរាយ កូនកុំចូលមកឡើយ ។ ព្រះពោធិសត្វបានតបទៅនឹង លោកទាំងពីរថា : បើដូច្នោះ សូមមាតាបិតាចាប់នូវចុង ឈើច្រត់នេះចុះ ហើយក៏ហុចនូវចុងឈើច្រត់វែង ជូន លោកទាំងពីរចាប់ ។ លោកទាំងពីរចាប់ចុងឈើច្រត់ ហើយក៏បានមករកបុត្រ ។ ព្រះពោធិសត្វសួរថា : ចក្ខុ របស់មាតាបិតាងងឹតទៅដោយសារអ្វី ? លោកទាំងពីរក៏ បានពោលរៀបរាប់ប្រាប់ព្រះពោធិសត្វថា : កូនអើយ កាលដែលភ្លៀងធ្លាក់ យើងទាំងពីរនាក់ ឈរនៅលើដំបូក ក្បែរគល់ឈើនោះ ហើយចក្ខុទាំងអស់ក៏ស្រាប់តែងងឹត តែម្តងទៅ ដោយហេតុនោះឯងណាំកូន ។ ព្រះពោធិសត្វ



បានស្តាប់ពាក្យរបស់មាតាបិតាហើយ ក៏ដឹងថាមានអាសិរ-ពិសនៅក្នុងរន្ធដំបូក អាសិរពិសនោះ គេខឹងក្រោធ ទើប បញ្ចេញខ្យល់តាមរន្ធច្រមុះមក ។ ព្រះពោធិសត្វ ឃើញ មាតាបិតាដូច្នេះហើយ ក៏យំរួចសើច ។ មាតាបិតាទើប សួរថា : កូនសម្លាញ់ម៉េចបានជាយំហើយសើចអីចឹង ? ព្រះពោធិសត្វតបថា : កូនយំដោយទោមនស្សខ្វចចិត្តដ្បិត ចក្ខុរបស់មាតាបិតាមានការវិនាសទៅ ទាំងដែលកូននៅ ក្មេងវ័យ តែកូនសើចដោយសេចក្តីសប្បាយចិត្តថា កូននឹង បានបដិបត្តិទំនុកបម្រុង ដល់មាតាបិតាជាអ្នកមានគុណ ទាំងពីរតទៅ សូមមាតាបិតា កុំគិតបារម្ភអ្វីឡើយ កូននឹង បម្រើឱ្យលោកទាំងពីរបានដល់នូវផាសុក ។ ព្រះពោធិសត្វ លួងលោមផ្លូវចិត្ត ឱ្យមាតាបិតាបានធូរក្នុងចិន្តា ហើយក៏ បាននាំមកកាន់បណ្ណសាលា ។ ព្រះពោធិសត្វរៀបចំចង ខ្សែជាស្នូបង្កាន់ដៃក្នុងទីទាំងពួង គឺទីសម្រាកពេលថ្ងៃ ទី សម្រាកពេលយប់ ទីចង្ក្រម បណ្ណសាលា និងទីបន្ទោបង់ ឧច្ចារៈបស្សាវៈ ។ ចាប់ផ្តើមតាំងពីនោះមក ព្រះពោធិសត្វ

បានឱ្យមាតាបិតានៅក្នុងអាស្រមបទ ខ្លួនឯងចេញទៅនាំយកមូលផលាផលពីក្នុងព្រៃ មកតាំងទុកក្នុងបណ្ណសាលា។ បោសសម្អាតទីនៅនៃមាតាបិតា តាំងពីព្រលឹមស្រាងៗ ថ្វាយបង្គំមាតាបិតាហើយ កាន់ក្អមទឹកទៅកាន់មិគសម្មតា-នទី ដងទឹកយកមក ហើយរៀបចំរបស់ឆាន់ ចាត់ចែងឈើជម្រះព្រះទន្តនិងទឹកខ្ពុរព្រះឱស្ឋជាដើម ហើយប្រគេនផលាផលដែលមានរសល្អប្រពៃ ។ កាលមាតាបិតាឆាន់រួចស្រេចហើយ ទើបខ្លួនឯងបានបរិភោគនូវផលាផលដែលសល់តាមក្រោយ ។ ស្រេចកិច្ចរឿងបរិភោគហើយ ក៏ក្រាបថ្វាយបង្គំលាមាតាបិតា មានហ្វូងម្រឹគហែហមអមយាត្រា ចូលកាន់ព្រៃព្រឹក្សាស្វែងរកមូលផលាផល ។ ពួកកិន្នរនៅនាជើងបព៌ត ហែហមព្រះពោធិសត្វជួយបេះផ្លែឈើតូចធំ រហូតដល់មេឃស្រទំស្រទន់ព្រះសុរិយា ទើបព្រះពោធិសត្វវិលវិញមកកាន់បណ្ណសាលានាអាស្រមបទ។ ព្រះពោធិសត្វបានទៅដងទឹក ហើយយកមកដាំក្នុងឆ្នាំងឱ្យក្តៅ ទើបផ្ងូតដល់មាតាបិតា ទាំងដុសលាងព្រះបាទាតាម



អធ្យាស្រ័យ រួចហើយជួយរៀបចំគ្រឿងស្លៀកដណ្តប់ និងយកថ្មដុតដោយភ្លើងមកដាក់កម្តៅចុងជើងចុងដៃ ដើម្បីកម្ចាត់បង់នូវភាពត្រជាក់រងា ។ ព្រះពោធិសត្វបដិបត្តិតាមតួនាទី ទំនុកបម្រុងមាតាបិតា ដោយប្រការដូច្នេះហោង។

ក្នុងសម័យនោះឯង ព្រះរាជាទ្រង់ព្រះនាមថា **បិលយក្ខរាជ** សោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី ព្រះអង្គទ្រង់ល្មោភចំពោះសាច់ម្រឹគក្នុងព្រៃ ទើបប្រគល់រាជសម្បត្តិឱ្យដល់ព្រះរាជជននីគ្រប់គ្រង ។ ទ្រង់ចងសៀតរាជាវុធ ៥ យ៉ាងចូលកាន់ហិមវន្តប្រទេស សម្លាប់ម្រឹគទាំងឡាយសប្បាយនឹងសោយសាច់ ស្តេចក៏បានយាងទៅដល់មិគសម្មតានទីដោយលំដាប់ រហូតយាងដល់កំពង់ដែលសុវណ្ណសាមព្រះពោធិសត្វដងទឹករាល់ថ្ងៃ ។ ព្រះរាជាបិលយក្ខបានទតព្រះនេត្រឃើញជាក់ នូវស្នាមជើងម្រឹគដ៏សន្ធឹកសន្ធាប់ ទ្រង់ក៏បានធ្វើស៊ុមដោយមែកឈើស្រស់ហើយត្រៀមព្រះអង្គនៅក្នុងស៊ុមនោះ ជាមួយនឹងធ្នូសរដែលលាបទៅដោយថ្នាំពិស ។ ចំណែកព្រះពោធិសត្វ នាំ

ផលាផលមកដល់ក្នុងវេលាល្ងាច ទុកដាក់ក្នុងបណ្ណសាលា អាស្រមបទ ថ្វាយបង្គំមាតាបិតារួចក៏ទៅដងទឹក មានហ្វូងម្រឹគហែហម ។ ព្រះពោធិសត្វ បានឱ្យម្រឹគមួយគូដើរកៀកគ្នា ហើយដាក់ក្អមទឹកលើខ្នងម្រឹគទាំងពីរនោះ នាំគ្នាដើរត្រសងទៅកាន់កំពង់ទឹក ។ ចំណែកព្រះរាជាទ្រង់ប្រថាប់នៅក្នុងស៊ុម ទតព្រះនេត្រឃើញព្រះពោធិសត្វដើរមក ទ្រង់គិតថា យើងត្រាច់មកកាន់ហិមវន្តប្រទេស រហូតអស់កាលត្រឹមនេះ នៅមិនទាន់ឃើញមានមនុស្សឡើយ តើបុគ្គលនេះជាទេវតាឬក៏ជានាគហ្ន៎ ។ ប្រសិនបើយើងនឹងចូលទៅសាកសួរបុគ្គលនេះ បើជាទេវតានឹងហោះឡើងទៅលើអាកាស ហើយបើជានាគវិញនោះនឹងមុជចុះទៅក្នុងដី ចំណែកយើងត្រាច់មកក្នុងព្រៃនាហិមវន្តប្រទេសនេះ អស់កាលរហូតក៏ទេដែរ ។ ដល់យើងត្រឡប់ទៅពារាណសីវិញ អាមាត្យទាំងឡាយនឹងសួរយើងថា កាលដែលព្រះអង្គយាងទៅហិមវន្តប្រទេស បានទតព្រះនេត្រឃើញអ្វីដែលអស្ចារ្យខ្លះ ។ កាលបើសួរដូច្នេះ យើងនឹង

-៣៣-

ប្រាប់ថា បានឃើញសត្វដូចនេះ ។ គេនឹងសួរដេញដោលថា សត្វនោះឈ្មោះអ្វី ។ កាលបើយើងឆ្លើយថាមិនស្គាល់ គេនឹងតិះដៀលយើង ។ ព្រោះហេតុនោះ យើងនឹងបាញ់បុគ្គលនេះ ធ្វើឱ្យដល់នូវទុព្វលភាពហើយ យើងនឹងសួរឱ្យដឹងរឿង ។ លំដាប់នោះ ក្នុងកាលដែលហ្វូងម្រឹគចុះផឹកទឹកហើយឡើងមក ព្រះពោធិសត្វទើបសន្សឹមៗចុះ បីដូចជាព្រះថេរៈដែលមានវត្តរៀបរយល្អហើយ ងូតទឹករម្ងាប់នូវការក្រវល់ក្រវាយកាយសមគួរហើយ ទើបឡើងមកស្លៀកសំពត់សំបកឈើពណ៌ក្រហមមួយផ្ទាំង ដណ្តប់មួយផ្ទាំង និងយកស្បែកខ្លាដាក់លើស្មា រួចហើយ ទើបលើកយកក្អមទឹកឡើងជូតបាតឱ្យស្អាត ដាក់លើស្មាខាងឆ្វេង ។ ក្នុងកាលនោះ ព្រះរាជាទ្រង់គិតថា ឥឡូវនេះ ជាកាលដែលសមគួរនឹងបាញ់ហើយ ទើបលើកធ្នូនិងសរដែលលាបទៅដោយថ្នាំពិសឡើង ហើយបាញ់ព្រះពោធិសត្វត្រូវខាងស្តាំ ធ្លុះចេញទៅខាងឆ្វេង ។ ហ្វូងម្រឹគដឹងថា ព្រះពោធិសត្វត្រូវគេបាញ់ ក៏តក់ស្លុតភ្ញាក់ផ្អើលរត់អស់ទៅ

-៣៤-

ចំណែកសុវណ្ណសាមបណ្ឌិត សូម្បីត្រូវព្រួញពិសក៏នៅទ្រក្អមទឹកទុកដោយប្រក្រតី មានស្មារតីដាក់ចុះក្រោម ដោយកាយដីខ្សាច់ឱ្យក្រហូងបន្តិច ទើបដាក់ក្អមទឹកឱ្យនឹងនៅទីនោះ រួចហើយកំណត់ទិស ទើបបែរសីសៈទៅខាងបណ្ណ-សាលា ដែលជាទីនៅនៃមាតាបិតា បីដូចសុវណ្ណបដិមាដែលដួលដេកនៅលើផ្ទៃខ្សាច់ពណ៌ប្រាក់ ដូច្នោះឯង ។ សុវណ្ណសាមព្រះពោធិសត្វ តាំងសតិពោលថា : បុគ្គលដែលមានពៀរនឹងយើង ក្នុងហិមវន្តប្រទេសនេះ មិនមានឡើយ ឯបុគ្គលដែលមានពៀរជាមួយនឹងមាតាបិតារបស់យើងក៏មិនមានដែរ ពោលដូច្នេះហើយ ក៏បានខ្ជាក់លោហិតចេញពីមាត់ ។ កាលដែលមិនបានឃើញព្រះរាជា ទើបពោលនូវគាថាសួរដូច្នេះថា :

**កោ នុ មំ ឧសុនា វិជ្ឈិ**
**បមត្តំ ឧទហារិកំ**
**ខត្តិយោ ព្រាហ្មណោ វេស្សោ**
**កោ មំ វិទ្ធា និលីយសិ ។**



នរណាហ្ន៎បាញ់ខ្ញុំជាអ្នកដងទឹក ដែលកំពុងភ្លឹកសតិបង់បាត់
ជាព្រាហ្មណ៍វេស្សៈឬក៏ជាក្សត្រ នរណាពួនស្កាត់បាញ់ខ្ញុំដោយសរ ។

បណ្ដាបទទាំងនោះ បទថា **បមត្តំ** ដោយសេចក្ដីថា បុគ្គលដែលមិនបានតាំងនូវសតិក្នុងការចម្រើនមេត្តា ។ ពាក្យនេះ ព្រះពោធិសត្វពោលសំដៅដល់សេចក្ដីថា បានធ្វើខ្លួនជាអ្នកប្រមាទក្នុងខណៈនោះ ។

បទថា **វិទ្ធា** ដោយសេចក្ដីថា បាញ់ហើយពួនកាយនៅក្នុងទីនេះ ជានរណាហ្ន៎ ក្សត្រឬព្រាហ្មណ៍ឬក៏ជាវេស្សៈប្រើកូនសរលាបថ្នាំពិស បាញ់ខ្ញុំដែលជាអ្នកដងទឹកពីមិគ-សម្មតានទី គឺជនឈ្មោះអ្វីហ្ន៎ បាញ់ខ្ញុំហើយពួនកាយបាត់ គឺបិទបាំងខ្លួនក្នុងគុម្ពព្រៃ ។

ក្នុងគ្រាដែលព្រះពោធិសត្វពោលយ៉ាងនេះហើយ ដើម្បីនឹងសម្ដែងភាពនៃមំសៈក្នុងសរីរៈរបស់ខ្លួនឱ្យឃើញថាមិនមែនជាភក្សាហារ ទើបពោលគាថាជាបន្តថា :

**ន មេ មំសានិ ខជ្ជានិ ចម្មេនត្ថោ ន វិជ្ជតិ**
**អថ កេន នុ វណ្ណេន វិទ្ធេយ្យំ មំ អមញ្ញថ ។**

សាច់ខ្ញុំមិនមែនជាម្ហូបអាហារ ស្បែកខ្ញុំនេះណាឥតការបរវរ
ហេតុអ្វីខ្ញុំនេះត្រូវបាញ់ដោយសរ សំគាល់ថាល្អបិតនៅត្រង់ណា ។

ក្នុងគាថានោះមានសេចក្ដីថា ម្នាលមាណពដ៏ចម្រើនអើយ សាច់របស់ខ្ញុំ គឺសាច់ក្នុងសរីរៈរបស់ខ្ញុំ បរិភោគមិនបាន គឺមនុស្សទាំងឡាយមិនគប្បីបរិភោគ ។ ឯស្បែករបស់ខ្ញុំ គឺស្បែកក្នុងសរីរៈរបស់ខ្ញុំ មិនមានប្រយោជន៍ដល់មនុស្សទាំងឡាយ ។ កាលបើដូច្នេះ បុរសនេះសំគាល់ថា ខ្ញុំគួរបាញ់ ដោយមិនពិចារណា ដោយវណ្ណៈអ្វី គឺដោយហេតុអ្វី ។

កាលដែលបានពោល ២ គាថារួចហើយ ដើម្បីនឹងសួរដល់ឈ្មោះជាដើម ព្រះពោធិសត្វទើបពោលគាថាសួរថា :

**កោ វា ត្វំ កស្ស វា បុត្តោ**
**កថំ ជានេមុ តំ មយំ**
**បុដ្ឋោ មេ សម្ម អក្ខាហិ**
**កឹ មំ វិទ្ធា និលីយសិ ។**



ឱសម្លាញ់អើយខ្ញុំសូមសួរអ្នក បាញ់ខ្ញុំហើយលាក់បំពួនអាត្មា
តើអ្នកជាអ្វីជាបុត្រអ្នកណា ខ្ញុំដឹងហេតុការណ៍បានដូចម្ដេចទៅ ។

កាលដែលព្រះពោធិសត្វពោលគាថាយ៉ាងនេះហើយ ក៏បាននៅស្ងៀមក្នុងថ្លុកឈាមនោះឯង ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ទើបគិតថា បុរសនេះសូម្បីត្រូវយើងបាញ់ដោយព្រួញលាបថ្នាំពិសដួលចុះហើយ ក៏មិនបានជេរយើង ហើយក៏មិនត្អូញត្អែរអ្វីដែរ បែរជាហៅរកយើងដោយពាក្យគួរជាទីស្រឡាញ់ទៅវិញ បេះដូងយើងដូចជាត្រូវគេអារដោយកាំបិត យើងនឹងទៅរកគេ ។ ព្រះរាជាទ្រង់គិតដូច្នេះហើយ ស្ដេចក៏យាងទៅប្រថាប់ឈរក្នុងទីជិតព្រះពោធិសត្វហើយពោលថា :

**រាជាហមស្មិ កាសីនំ បិលយក្ខោតិ មំ វិទូ**
**លោភា រដ្ឋំ បហិត្វាន មិគមេសំ ចរាមហំ ។**

គេស្គាល់ឈ្មោះខ្ញុំថាបិលយក្ខ ជាស្ដេចនៃអ្នកក្នុងដែនកាសី
ខ្ញុំលះបង់ដែនស្វែងរកម្រឹគព្រៃ ព្រោះលោភនឹងឆីសោយរសមំសំ ។

**ឥស្សត្ថេ ចស្មិ កុសលោ ឧឡ្ហធម្មោតិ វិស្សុតោ**
**នាគោបិ មេ ន មុញ្ចេយ្យ អាគតោ ឧសុបាតនំ ។**

ម្យ៉ាងទៀតខ្ញុំល្បីរ៉ៃខាងសិល្បសាស្ត្រ ធ្នូសរខ្ញុំច្បាស់បាញ់ពេញកម្លាំង
សត្វណាមកចំមុខព្រួញខ្ញុំតាំង ទោះដំរីខ្លាំងមិនរួចដេកដី ។

បណ្ដាបទទាំងនោះ បទថា **រាជាហមស្មិ** ដោយសេចក្ដីថា ព្រះបាទបិលយក្ខនោះ មានព្រះតម្រិះយ៉ាងនេះថា ទេវតាក៏ដោយនាគក៏ដោយ រមែងនិយាយភាសាមនុស្សបានទាំងអស់ យើងមិនដឹងថាបុគ្គលនេះជាទេវតាឬនាគ ឬក៏ជាមនុស្សឡើយ បើគេក្រោធ នឹងធ្វើឱ្យយើងវិនាសទៅបាន ដូច្នេះកាលបើប្រាប់ថាយើងជាព្រះរាជាអ្នកណាៗដែលមិនខ្លាច រមែងមិនមានឡើយ ។ កាលបើព្រះតម្រិះដូច្នេះហើយ ដើម្បីនឹងឱ្យដឹងថាព្រះអង្គជាព្រះ-រាជា ទើបបានត្រាស់ជាមុនថា **រាជាហមស្មិ** ម្នាលមាណពយើងជាព្រះរាជារបស់អ្នកដែនកាសី គឺពួកជនដែលនៅក្នុងកាសិករដ្ឋដូច្នេះឯង ។

បទថា **មំ** បានដល់ ប្រជាជនស្គាល់យើងដោយ



នាមថា **ព្រះបាទបិលយក្ខ** ។

បទថា **វិទូ** បានដល់ ស្គាល់គឺហៅ ។

បទថា **លោភា** ដោយសេចក្ដីថា បានប្រគល់រាជ-សម្បត្តិដល់ព្រះជននី ព្រោះមានសេចក្ដីល្មោភនឹងសាច់ម្រឹគ ។

បទថា **មិគមេសំ** បានដល់ ស្វែងរក គឺរុករកនូវពួកម្រឹគ ។

បទថា **ចរាមហំ** ដោយសេចក្ដីថា យើងត្រាច់ទៅក្នុងព្រៃតែម្នាក់ឯងប៉ុណ្ណោះ ។ ព្រះរាជាបំណងនឹងសម្ដែងនូវកម្លាំងរបស់ព្រះអង្គ ទើបត្រាស់នូវគាថាទី ២ ។

បទថា **ឥស្សត្ថេ** បានដល់ ក្នុងធ្នូសិល្ប៍ ។

បទថា **ឧឡ្ហធម្មោ** ដោយសេចក្ដីថា ជាអ្នកទ្រទ្រង់នូវកម្លាំង អាចយឹតធ្នូដ៏ធ្ងន់បាន គឺធ្នូមានទម្ងន់ដែលបុរសធម្មតាមួយពាន់នាក់ទើបអាចលើករួចបាន រឿងនេះបានល្បីទៅប្រាកដពេញជម្ពូទ្វីប ។

បទថា **អាគតោ ឧសុបាតនំ** ដោយសេចក្ដីថា ដំរី

ដែលមានកម្លាំងមកចំមុខព្រួញរបស់យើង ក៏មិនអាចផុតចាកពីកន្លែងទៅបាន ៧ ជំហានឡើយ ។

ព្រះរាជា ទ្រង់សរសើរកម្លាំងរបស់ព្រះអង្គ ដូចនេះហើយ កាលដែលនឹងត្រាស់សួរនាមនិងគោត្ររបស់ព្រះពោធិសត្វ ទើបត្រាស់ថា :

**កោ វា ត្វំ កស្ស វា បុត្តោ កថំ ជានេមុ តំ មយំ**
**បិតុនោ អត្តនោ ចាបិ នាមគោត្តំ បវេទយ ។**

ចុះអ្នកជាអ្វីជាបុត្រនរណា យើងម្ដេចដឹងថាអ្នកមានឈ្មោះអ្វី
ព្រមទាំងត្រកូលបិតាផងនៃ សូមអ្នកស្រដីប្រាប់យើងឱ្យស្គាល់ ។

បណ្ដាបទទាំងនោះ បទថា **បវេទយ** ប្រែថា គប្បីប្រាប់ ។

ព្រះពោធិសត្វ បានស្ដាប់ដូច្នោះហើយ ទើបគិតថា យើងជាទេវតា នាគ យក្ស កិន្នរ ឬថាជាក្សត្រជាដើម យ៉ាងណាមួយ ព្រះរាជានេះក៏គង់តែជឿពាក្យរបស់យើងដែរ ប៉ុន្តែយើងគួរពោលតែពាក្យពិតប៉ុណ្ណោះ លុះគិតដូច្នេះហើយ ទើបពោលថា :



**នេសាទបុត្តោ ភទ្ទន្តេ សាមោ ឥតិ មំ ញាតយោ**
**អាមន្តយិំសុ ជីវន្តំ ស្វាជ្ជេវង្គតោ សយេ ។**

ខ្ញុំកូនឥសីបុត្រអ្នកនេសាទ ពេលរស់ពួកញាតិហៅខ្ញុំថាសាម
ទ្រង់អើយថ្ងៃនេះខ្ញុំត្រូវមារតាម មច្ចុចាប់ច្បាមផ្ដេកលើប្រឹថពី ។

**វិទ្ធោស្មិ បុថុសល្លេន សវិសេន យថា មិគោ**
**សកម្ហិ លោហិតេ រាជ បស្ស សេមិ បរិប្លុតោ ។**

ដូចព្រានបាញ់ម្រឹគដែលទ្រង់បាញ់ខ្ញុំ ដោយព្រួញពិសធំបាញ់ចំពេញទី
ខ្ញុំត្រាំឈាមឯងដេកលើធរណី ព្រួញពិសយាយីទ្រង់ទតឃើញពិត ។

**បដិវាមគតំ សល្លំ បស្ស ថិម្ហាមិ លោហិតំ**
**អាតុរោ ត្យានុបុច្ឆាមិ កឹ មំ វិទ្ធា និលីយសិ ។**

សូមទ្រង់ទតព្រួញមុតស្ដាំធ្លាយឆ្វេង ឈឺពើតក្រៃលែងមាត់ខ្ពុរលោហិត
ខ្ញុំសួររឿយៗចំពោះបពិត្រ ទ្រង់ឃីតបាញ់ហើយម្ដេចឡើយលាក់កាយ ។

**អជិនម្ហិ ហញ្ញតេ ទីបិ នាគោ ទន្តេហិ ហញ្ញតេ**
**អថ កេន នុ វណ្ណេន វិទ្ធេយ្យំ មំ អមញ្ញថ ។**

សម្លាប់ខ្លាដំបងប៉ងយកស្បែក ចំណែកដំរីព្រោះភ្លុកទាំងឡាយ
ឯទូលបង្គំព្រោះអ្វីក្នុងកាយ ទើបទ្រង់ខ្វល់ខ្វាយចំណាយពេលបាញ់ ។

បណ្ដាបទទាំងនោះ បទថា **ភទ្ទន្តេ** ដោយសេចក្តី

ថា បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ព្រះចម្រើន ខ្ញុំព្រះអង្គជាបុត្រឥសីដែលឥសីនោះជាបុត្រនាយព្រាន ។

បទថា **ជីវន្តំ** ដោយសេចក្តីថា ញាតិទាំងឡាយកាលដែលហៅឈ្មោះទូលបង្គំ ពេលដែលនៅមានជីវិតមុននេះថា : សាមមកនេះ សាមទៅនោះ គឺហៅឈ្មោះថា **សាម** ។

បទថា **ស្វាជ្ជេវទន្តតោ** ដោយសេចក្តីថា ថ្ងៃនេះខ្ញុំព្រះអង្គនោះ ទៅដល់ គឺចូលទៅក្នុងមាត់នៃមរណៈហើយយ៉ាងនេះឯង ។

បទថា **សយេ** ប្រែថា ដេកនៅ ។

ម្រឹគត្រូវព្រានព្រៃបាញ់ដោយព្រួញដ៏ធំ លាបទៅដោយថ្នាំពិស យ៉ាងណា សូម្បីខ្ញុំព្រះអង្គក៏ជាអ្នកដែលត្រូវព្រះអង្គបាញ់យ៉ាងនោះឯង ។

បទថា **បរិប្លុតោ** ដោយសេចក្តីថា ដេកត្រាំ ។ សូមព្រះអង្គទ្រង់ទតព្រះនេត្រមើលនូវខ្ញុំព្រះអង្គដែលដេកមានសភាពបែបនេះ ។



បទថា **បដិវាមគតំ** ដោយសេចក្តីថា ចូលពីខាងស្តាំហើយផ្លុះចេញទៅខាងឆ្វេង ។

បទថា **បស្ស** បានដល់ សូមទតព្រះនេត្រមើលខ្ញុំព្រះអង្គ ។

បទថា **ជិម្ហាមិ** ប្រែថា ខ្ពុរ ។ ព្រះពោធិសត្វនោះតាំងសតិមាំ មិនញាប់ញ័រឡើយ ខ្ជាក់លោហិត ត្រាស់ហើយដោយប្រការដូច្នេះ ។

បទថា **អាតុរោ** ដោយសេចក្តីថា ខ្ញុំព្រះអង្គឈឺពើតណាស់ សូមទូលសួរព្រះអង្គ ។

បទថា **និលីយសិ** ដោយសេចក្តីថា ប្រថាប់អង្គុយនៅក្នុងគុម្ពឈើមួយ ។

បទថា **វិទ្ធេយ្យំ** ប្រែថា គួរបាញ់ ។

បទថា **អមញ្ញថ** ដោយសេចក្តីថា បានយល់ថាដូចម្រឹគ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ព្រះពោធិ-សត្វហើយ មិនត្រាស់ប្រាប់តាមសេចក្តីពិត កាលដែលនឹង

ត្រាស់នូវពាក្យកុហក ទើបត្រាស់ថា :

**មិគោ ឧបដ្ឋិតោ អាសិ    អាគតោ ឧសុឃាតនំ**
**តំ ទិស្វា ឧព្វិជ្ជិ សាម    តេន កោធោ មមាវិសិ ។**

ម្រឹគមកប្រាកដចំមុខព្រួញខ្ញុំ    ឃើញអ្នកជាធំក៏ផ្អើលអស់ទៅ
ព្រោះហេតុនោះទើបចិត្តក្រោធគ្របនៅ បង្វែរព្រួញទៅបាញ់សាមដងទឹក ។

បណ្ដាបទទាំងនោះ បទថា **ឧព្វិជ្ជិ** ប្រែថា ផ្អើលរត់អស់ទៅ ។

បទថា **អាវិសិ** បានដល់ គ្របសង្កត់ ។ ព្រះរាជាទ្រង់សម្ដែងថា សេចក្ដីក្រោធកើតឡើងដល់យើង ព្រោះហេតុនោះឯង ។

លំដាប់នោះ ព្រះពោធិសត្វទូលព្រះរាជាថា បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ព្រះអង្គត្រាស់អ្វីហ្នឹង ដែលថាម្រឹគឃើញខ្ញុំព្រះអង្គហើយរត់គេចទៅនោះ មិនមានក្នុងហិមវន្តប្រទេសនេះឡើយ ហើយក្រាបទូលដោយព្រះគាថាថា :

**យតោ សរាមិ អត្តានំ    យតោ បត្តោស្មិ វិញ្ញុតំ**



**ន មំ មិគា ឧត្រាសន្តិ    អរញ្ញេ សាបទានិបិ ។**

តាំងពីខ្ញុំដឹងអ្វីខុសអ្វីត្រូវ    សត្វព្រៃទូទៅដោយច្រើនពួកម្រឹគ
ទោះសត្វសាហាវក៏ច្រើនសន្ធឹក    មិនដែលភ្លូកភ្លឹកផ្អើលនឹងខ្ញុំឡើយ ។

**យតោ និធឹ បរិហរឹ    យតោ បត្តោស្មិ យោព្វនំ**
**ន មំ មិគា ឧត្រាសន្តិ    អរញ្ញេ សាបទានិបិ ។**

តាំងពីខ្ញុំបានចេះស្លៀកដណ្ដប់    ចេះដឹងគ្រប់សព្វវ័យចម្រើនហើយ
គឺថាពាឡម្រឹគមិនផ្អើលខ្ញុំឡើយ    ជិតខ្ញុំបង្អើយម្រឹគមិនតក់ស្លុត ។

**ភីរូ កឹបុរិសា រាជ    បព្វតេ គន្ធមាទនេ**
**សម្មោទមានា គច្ឆាម    បព្វតានិ វនានិ ច**
**អថ កេន នុ វណ្ណេន    ឧត្រាសន្តិ មិគា មមំ ។**

បពិត្រមហារាជដ៏ចម្រើនអើយ    កិន្នរហ្នឹងហើយតែងខ្លាចបំផុត
នៅភ្នំគន្ធមាទន៍ព្រៃភ្នំបរិសុទ្ធ    តែនៅមិនស្លុតនឹងទូលបង្គំ ។
ពួកយើងតែងតែរីករាយនឹងគ្នា    ទៅព្រៃនានាឬក៏ឡើងភ្នំ
ដូច្នោះពួកម្រឹគផ្អើលអីនឹងខ្ញុំ    ពីតូចដល់ធំខ្ញុំនៅនឹងម្រឹគ ។

បណ្ដាបទទាំងនោះ បទថា **ន មំ មិគា** ដោយសេចក្ដីថា ធម្មតាម្រឹគទាំងឡាយឃើញខ្ញុំព្រះអង្គហើយ

រមែងមិនភ័យខ្លាចតក់ស្លុតឡើយ ។

បទថា **សាបទានិ** បានដល់ ពាឡម្រឹគ ។

បទថា **យតោ និធឹ** ដោយសេចក្តីថា ចាប់ផ្តើមតាំងពីកាលដែលទូលបង្គំស្លៀកដណ្តប់ គឺទ្រទ្រង់សំពត់សំបកឈើ ។

បទថា **តិរូ តិំបុរិសា រាជ** ដោយសេចក្តីថា បពិត្រព្រះរាជាដ៏ជាធំ ម្រឹគទាំងឡាយ ចូរលើកទុកសិនចុះ ពោលពីធម្មតានៃកិន្នរទាំងឡាយ រមែងជាអ្នកភ័យខ្លាចដ៏ក្រៃលែង ប៉ុន្តែកិន្នរទាំងឡាយណាដែលនៅភ្នំគន្ធមាទន៍នេះ កិន្នរទាំងឡាយនោះ ឃើញខ្ញុំព្រះអង្គហើយ រមែងមិនភ័យតក់ស្លុតឡើយ តាមពិតពួកយើងរីករាយជាមួយគ្នាទៅវិញទៅមក ទៅតាមព្រៃភ្នំ ។

បទថា **ឧត្រាសន្តិ មិគា មមំ** ដោយសេចក្តីថា ព្រះពោធិសត្វសម្តែងនូវសេចក្តីថា ព្រោះហេតុអ្វី ទើបព្រះអង្គឱ្យខ្ញុំព្រះអង្គជឿថា ម្រឹគទាំងឡាយឃើញខ្ញុំព្រះអង្គហើយ ភ័យតក់ស្លុតនោះ ។



ព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ទ្រង់ព្រះតម្រិះថា យើងបាញ់សាម ដែលជាអ្នកមិនមានកំហុសនេះហើយ នៅពោលមុសាវាទទៀត ឥឡូវយើងនឹងពោលតែពាក្យពិតប៉ុណ្ណោះ ដូច្នេះហើយ ទើបត្រាស់ថា :

**ន តំ តស មិគោ សាម កិន្តាហំ អលិកំ ភណេ**
**កោធលោភាភិភូតាហំ ឧសុំ តេ តំ អវិស្សជឹ ។**

ម្រឹគមិនមែនផ្អើលនឹងសាមទេណា ខ្ញុំនឹងមុសាធ្វើអ្វីទៀតនោះ
ដ្បិតក្រោធនិងលោភវាគ្របឱ្យលុះ ទើបខ្ញុំគិតខុសបាញ់សាមនឹងសរ ។

បណ្តាបទទាំងនោះ បទថា **ន តទ្ធស**(១) ដោយសេចក្តីថា ម្រឹគឃើញអ្នកហើយមិនភ្ញាក់ផ្អើលតក់ស្លុតទេ។

បទថា **កិន្តាហំ** ដោយសេចក្តីថា យើងពោលកុហកក្នុងសំណាក់របស់អ្នក ដែលមានទស្សនៈល្អប្រពៃយ៉ាងនេះទៀតឬ ។

បទថា **កោធលោភាភិភូតាហំ** ដោយសេចក្តីថា យើងជាអ្នកដែលមានសេចក្តីក្រោធនិងសេចក្តីលោភគ្របសង្កត់ហើយ ។ គឺកាលដែលម្រឹគទាំងឡាយ ចុះទៅមុន

១-បាលីបិដក = **ន តំ តស** ។

នោះឯង ព្រះរាជានោះនឹងបាញ់ម្រឹគទាំងឡាយ ព្រោះសេចក្តីក្រោធ ហើយក៏បានលើកធ្នូ ។ ក្រោយមកបានឃើញ ព្រះពោធិសត្វ មិនដឹងថាព្រះពោធិសត្វនោះគឺជាអ្វីមួយក្នុងបណ្តាទេវតាជាដើម នឹងសួរព្រះពោធិសត្វនោះ ព្រះរាជាញុំាងសេចក្តីលោភឱ្យកើតឡើង ដោយប្រការដូច្នេះ ព្រោះហេតុនោះទើបត្រាស់យ៉ាងនេះ ។

កាលដែលត្រាស់យ៉ាងនេះហើយ ព្រះរាជាទ្រង់ព្រះតម្រិះថា សាមនេះ នឹងមិនមែនអាស្រ័យនៅក្នុងព្រៃនេះតែម្នាក់ឯងទេ ញាតិទាំងឡាយរបស់គេគប្បីមានជាប្រាកដ យើងនឹងសួរគេមើល ទើបត្រាស់គាថាទៀតថា :

**កុតោ នុ សាម អាគម្ម កស្ស វា បហិតោ តុវំ**
**ឧទហារោ នទឹ គច្ឆ អាគតោ មិគសម្មតំ ។**

សាមអើយអ្នកមកពីប្រទេសណា ឬថាអ្នកណាប្រើឱ្យត្រាច់ចរ
ថាអ្នកទៅដងទឹកស្ទឹងថ្លាល្អ ទើបចរមកកាន់មិគសម្មតា ។

បណ្តាបទទាំងនោះ ព្រះរាជាត្រាស់ហៅព្រះពោធិសត្វ ដោយបទថា **សាម** ។

-៤៩-

បទថា **អាគម្ម** ដោយសេចក្តីថា ចាកប្រទេសណាមកកាន់ព្រៃនេះ ។

បទថា **កស្ស វា បហិតោ** ដោយសេចក្តីថា អ្នកត្រូវនរណាប្រើដោយពាក្យថា ចូរទៅកាន់ស្ទឹងដើម្បីនាំទឹកមកដល់ពួកយើង ដូច្នេះ ទើបមកកាន់ស្ទឹងមិគសម្មតានេះ។

ព្រះពោធិសត្វ បានស្តាប់នូវព្រះតម្រាស់របស់ព្រះ-រាជាហើយ អត់ទ្រាំចំពោះទុក្ខវេទនាដ៏ខ្លាំងក្លា ខ្ពុរព្រះលោហិតហើយពោលព្រះគាថាថា :

**អន្ធា មាតាបិតា មយ្ហំ តេ ភរាមិ ព្រហាវនេ**
**តេសាហំ ឧទកហារោ អាគតោ មិគសម្មតំ ។**

ខ្ញុំអ្នកចិញ្ចឹមមាតាបិតា លោកខ្វាក់នេត្រានៅក្នុងមហាវ័ន
ខ្ញុំដងទឹកថ្វាយដល់ព្រះអរហន្ត រួសរាន់មកកាន់សម្មតានទី ។

បណ្តាបទទាំងនោះ បទថា **ភរាមិ** ដោយសេចក្តីថា នាំមូលផលាផលជាដើម មកចិញ្ចឹមបីបាច់ថែរក្សា ។

កាលដែលសុវណ្ណសាមព្រះពោធិសត្វ ពោលយ៉ាងនេះហើយក៏ពិលាបរៀបរាប់ដល់មាតាបិតាដោយគាថាថា:

-៥០-

**អត្ថិ នេសំ ឧសាមត្តំ   អថ សាហស្ស ជីវិតំ**
**ឧទកស្ស អលាភេន   មញ្ញេ អន្ធា មរិស្សរេ ។**

មាតាបិតាមានត្រឹមអាហារ   មិនដល់សប្តាហ៍រក្សាជីវី
ព្រោះគាត់ងងឹតខ្វាក់ភ្នែកទាំងពីរ   នឹងក្ស័យជីវីដោយសារអត់ទឹក ។

**ន មេ ឥទំ តថា ទុក្ខំ   លព្ភា ហិ បុមុនា ឥទំ**
**យញ្ច អម្មំ ន បស្សាមិ   តំ មេ ទុក្ខតរំ ឥតោ ។**

ទុក្ខត្រូវព្រួញនេះមិនសូវប៉ុន្មាន   បុរសត្រូវបានប៉ុន្តែការនឹក
មិនឃើញមាតាទុក្ខក្រៃពន្លឹក  ទុក្ខច្រើនព្រោះនឹកដល់អ្នកមានគុណ ។

**ន មេ ឥទំ តថា ទុក្ខំ   លព្ភា ហិ បុមុនា ឥទំ**
**យញ្ច តាតំ ន បស្សាមិ   តំ មេ ទុក្ខតរំ ឥតោ ។**

ទុក្ខត្រូវព្រួញនេះមិនសូវប៉ុន្មាន   បុរសត្រូវបានប៉ុន្តែទុក្ខធ្ងន់
មិនឃើញបិតាទុក្ខក្រៃពេកពន់  ទុក្ខច្រើនលើសលន់ច្រើនជាងត្រូវព្រួញ ។

**សា នូន កបណា អម្មា   ចិរំ រត្តាយ រុច្ឆតិ**
**អឌ្ឍរត្តេវ រត្តេ វា   នទីវ អវសុស្សតិ ។**

ឱម្ល៉េះសមម្តាយនឹងនៅកំព្រា   ចិរទិវារាត្រីយំទួញ
អធ្រាត្រយប់ស្ងាត់មានតែទំនួញ   យំទួញរីងខះដូចស្ទឹងខែប្រាំង ។



**សោ នូន កបណោ តាតោ   ចិរំ រត្តាយ រុច្ឆតិ**
**អឌ្ឍរត្តេវ រត្តេ វា   នទីវ អវសុស្សតិ ។**

ឱម្ល៉េះសមឪនឹងនៅកំព្រា   ចិរទិវារាត្រីទុក្ខំ
អធ្រាត្រយប់ស្ងាត់យំរីតតែខ្លាំង   ដូចស្ទឹងខែប្រាំងទុក្ខំសោកសៅ ។

**ឧដ្ឋានបាទចរិយាយ   រាជ សម្ពាហនស្ស ច**
**សាម តាត វិលបន្តា   ហិណ្ឌិស្សន្តិ ព្រហាវនេ ។**

ម្យ៉ាងទៀតខ្ញុំក្រោកមួយយប់ច្រើនគ្រា បម្រើបាទាច្របាច់គក់ភ្លៅ
ឥឡូវបាត់ខ្ញុំលោកនឹងដើរហៅ   ទៅក្នុងព្រៃជ្រៅអើយសាមកូនហ្ន៎ា ។

**ឥទម្បិ ទុតិយំ សល្លំ   កម្បេតិ ហទយំ មម**
**យញ្ច អន្ធេ ន បស្សាមិ   មញ្ញេ ហិស្សាមិ ជីវិតំ ។**

ហឫទ័យនៃខ្ញុំត្រូវសរទីពីរ   កក្រើករក់រីដោយសរសោកា
ព្រោះមិនបានឃើញអ្នកខ្វាក់នេត្រា  ជីវិតខ្ញុំរ៉ាមុខជាសាបសូន្យ ។

បណ្តាបទទាំងនោះ បទថា **ឧសាមត្តំ** បានដល់ត្រឹមតែអាហារ ។ បានឮថា ពាក្យថា **ឧសា** ជាឈ្មោះនៃភោជនាហារ ដោយសេចក្តីថា មាតាបិតាទាំងពីរនោះនៅមានភោជនាហារ ។

បទថា **អថ សាហស្ស ជីវិតំ** ដោយសេចក្តីថា មានជីវិតនៅបានប្រមាណ ៦ ថ្ងៃ ។ ព្រះពោធិសត្វពោលពាក្យនេះ សំដៅដល់ផលាផល ដែលនាំមកតាំងទុក ។ ម្យ៉ាងទៀត **ឧសា** បានដល់ ភ្លើងធាតុ ដោយបទនេះ ព្រះពោធិសត្វ សម្តែងដល់សេចក្តីនេះថា ក្នុងរាងកាយរបស់មាតាបិតាទាំងពីរនោះ មាននៅត្រឹមតែភ្លើងធាតុ កាលបើដូច្នោះ ក៏នឹងមានជីវិតទៅបាន ៦ថ្ងៃ ដោយផលាផលដែលខ្ញុំព្រះអង្គនាំមក ។

បទថា **មរិស្សរេ** ប្រែថា នឹងស្លាប់ ។

បពិត្រព្រះរាជាដ៏ជាធំ សេចក្តីទុក្ខព្រោះត្រូវព្រះអង្គបាញ់នេះ ជាទុក្ខក៏ពិតមែនហើយ ប៉ុន្តែមិនមែនជាសេចក្តីទុក្ខរបស់ខ្ញុំព្រះអង្គឡើយ ព្រោះហេតុអ្វីទើបពោលដូច្នេះ ។

បទថា **ចុម្មុនា** បានដល់ ដែលបុរស ដោយសេចក្តីថា សេចក្តីទុក្ខមានសភាពបែបនេះ ដែលបុរសគប្បីបានជួបប្រសព្វទាំងអស់នោះឯង ក៏ឯសេចក្តីទុក្ខ ដែលខ្ញុំព្រះ-



អង្គមិនបានឃើញ លោកម៉ែបាវិកានោះ ទើបជាសេចក្តីទុក្ខរបស់ខ្ញុំព្រះអង្គក្រៃលែងជាងសេចក្តីទុក្ខព្រោះត្រូវព្រះ-អង្គបាញ់ដោយព្រួញពិសនេះ មួយរយដង មួយពាន់ដង មួយសែនដង ។

បទថា **ចិរំ រត្តាយ រុច្ចតិ** ដោយសេចក្តីថា នឹងទួញយំរហូតអស់រាត្រីដ៏យូរ ។

បទថា **អឌ្ឍរត្តេ** បានដល់ ក្នុងសម័យពាក់កណ្តាលនៃរាត្រី ។

បទថា **រត្តេ ទិវា** បានដល់ ក្នុងទីបំផុតនៃរាត្រី ។

បទថា **អវសុស្សតិ** បានដល់ នឹងហួតហែង អធិប្បាយថា នឹងហួតហែងទៅដូចស្ទឹងតូចក្នុងរដូវក្តៅ ។

បទថា **ឧដ្ឋានបាទចរិយាយ** ដោយសេចក្តីថា បពិត្រព្រះរាជាដ៏ជាធំ ខ្ញុំព្រះអង្គក្រោកឡើង ក្នុងមួយយប់ពីរទៅបីដង ឬមួយថ្ងៃ ពីរទៅបីដង បដិបត្តិបម្រើមាតាបិតាទាំងពីរនោះ ច្របាច់ដៃ ច្របាច់ជើងរបស់លោកទាំងពីរនោះ ដោយសេចក្តីព្យាយាមនៃខ្ញុំព្រះអង្គ ឥឡូវនេះ

លោកទាំងពីរដែលជាអ្នកមានភ្នែកងងឹតនោះ មិនឃើញខ្ញុំព្រះអង្គក្រោកឡើងដើម្បីបដិបត្តិបម្រើនោះៗ នឹងពិលាបសោកាថា : កូនសាម កូនសាម នឹងត្រូវបន្ទាមុតចំពោះការដែលត្រាច់ទៅក្នុងហិមវន្តប្រទេសនេះ ។

បទថា **ទុតិយំ** ដោយសេចក្តីថា កូនសរ គឺសេចក្តីសោក ព្រោះមិនបានឃើញមាតាបិតាទាំងពីរនោះ គឺសេចក្តីទុក្ខទីពីរនេះ ជាសេចក្តីទុក្ខជាងដែលត្រូវព្រួញពិសបាញ់លើកទីមួយ មួយរយដង មួយពាន់ដង មួយសែនដង។

ព្រះរាជាទ្រង់ព្រះសណ្តាប់នូវការរៀបរាប់ពិលាបសោការបស់ព្រះពោធិសត្វហើយ ទ្រង់គិតថា បុរសនេះជាអ្នកតាំងនៅក្នុងធម៌ដ៏ប្រសើរ បានបដិបត្តិមាតាបិតាដ៏ប្រពៃក្រៃលែង ឥឡូវនេះ បានដល់នូវសេចក្តីទុក្ខមានសភាពបែបនេះហើយ នៅពិលាបរៀបរាប់ដល់មាតាបិតាទៀត ។ យើងបានធ្វើខុសក្នុងបុរសដែលសម្បូណ៌ដោយគុណធម៌យ៉ាងនេះ ដូច្នេះយើងគួរតែលួងលោមយកចិត្ត



បុរសនេះយ៉ាងណាល្អទៅហ្ន៎ ។ ហើយទ្រង់សន្និដ្ឋានថាក្នុងវេលាដែលយើងធ្លាក់នរក រាជសម្បត្តិនឹងធ្វើអ្វីបាន យើងនឹងបដិបត្តិមាតាបិតានៃបុរសនេះ ដោយទំនងដែលបុរសនេះធ្លាប់បដិបត្តិហើយ ការស្លាប់របស់បុរសនេះហាក់ដូចជាការមិនស្លាប់ ដោយប្រការដូច្នេះ ទើបត្រាស់ព្រះគាថាថា :

**មា ពាឡ្ហំ បរិទេវេសិ   សាម កល្យាណទស្សន**
**អហំ កម្មករោ ហុត្វា   ភរិស្សន្តេ ព្រហាវនេ ។**

ឱសាមកល្យាណគួរឱ្យទស្សនា   អ្នកកុំសោកាទួញយំខ្លាំងឡើយ
យើងរ៉ាប់ធ្វើការចិញ្ចឹមលោកហើយ ជំនួសអ្នកអើយនៅក្នុងព្រៃធំ ។

**ឥស្សត្ថេ ចស្មិ កុសលោ   ទឡ្ហធម្មោតិ វិស្សុតោ**
**អហំ កម្មករោ ហុត្វា   ភរិស្សន្តេ ព្រហាវនេ ។**

ម្យ៉ាងទៀតខ្ញុំឈ្លាសក្នុងសិល្បៈធ្នូ   ល្បីអស់កាលយូរទ្រង់ធ្នូខ្លាំងមាំ
យើងរ៉ាប់ធ្វើការចិញ្ចឹមថែទាំ   នៅក្នុងព្រៃធំនទីបព្វតា ។

**មិគានំ វិឃាសមន្វេសំ   វនមូលផលានិ ច**
**អហំ កម្មករោ ហុត្វា   ភរិស្សន្តេ ព្រហាវនេ ។**

ខ្ញុំធ្វើការងាររករំពាម្រឹគ    មើមឈើផ្លែស្លឹកក្នុងព្រៃព្រឹក្សា
ដើម្បីចិញ្ចឹមជនទាំងនោះណា    ក្នុងព្រៃបព្វតាទឹកធ្លាក់ចាកទី ។

**ភតមន្នំ វនំ សាម    យត្ថ មាតាបិតា តវ**
**អហន្តេ តថា ភរិស្សំ    យថា តេ អភរី តុវំ ។**

ឪពុកម្ដាយសាមនៅក្នុងព្រៃណា    ព្រៃដូចម្ដេចវ៉ាឋានអ្នកទាំងពីរ
អ្នកបានចិញ្ចឹមដោយការសំភី    យ៉ាងណានាទីខ្ញុំយ៉ាងនោះដែរ ។

បណ្ដាបទទាំងនោះ បទថា **ភរិស្សន្តេ** ដោយសេចក្ដីថា យើងនឹងចិញ្ចឹមមាតាបិតារបស់អ្នក ។

បទថា **មិគានំ** បានដល់ រាជសីហ៍ ខ្លាធំ ខ្លាដំបង និងម្រឹគជាដើម ។

បទថា **វិឃាសមន្វេសំ** ដោយសេចក្ដីថា ស្វែងរក គឺរុករកនូវអាហារ ។ ព្រះរាជាត្រាស់ថា : យើងជាអ្នកឆ្លាតក្នុងសិល្បធ្នូ នឹងសម្លាប់ម្រឹគធាត់ៗ ចិញ្ចឹមមាតាបិតារបស់អ្នក ដោយមំសៈដ៏មានឱជារសឆ្ងាញ់ ។ កាលដែលព្រះពោធិសត្វពោលថា : បពិត្រមហារាជដ៏ជាធំ ព្រះអង្គកុំសម្លាប់សត្វព្រោះហេតុពួកទូលព្រះបង្គំឡើយ ។ ព្រះ-



រាជាទ្រង់ព្រះសណ្ដាប់ហើយ ទើបទ្រង់ត្រាស់ដោយគាថាជាបន្តនោះឯង ។

បទថា **យថា តេ** ដោយសេចក្ដីថា អ្នកបានចិញ្ចឹមនូវលោកទាំងពីរនោះយ៉ាងណា សូម្បីខ្ញុំក៏នឹងចិញ្ចឹមលោកទាំងពីរនោះ យ៉ាងនោះដូចគ្នាដែរ ។

លំដាប់នោះ ព្រះពោធិសត្វបានស្ដាប់ព្រះវាចារបស់ព្រះរាជានោះហើយ ទើបទូលថា : ល្អហើយព្រះអង្គដ៏ចម្រើន បើយ៉ាងនោះ សូមព្រះអង្គមេត្តាប្រោសជួយចិញ្ចឹមបីបាច់ថែរក្សានូវមាតាបិតានៃទូលព្រះបង្គំជាខ្ញុំផងចុះ ។ កាលដែលនឹងចង្អុលបង្ហាញផ្លូវឱ្យទ្រង់ជ្រាបទើបទូលថា :

**អយំ ឯកបទី រាជ    យោយំ ឧស្សីសកេ មម**
**ឥតោ គន្ត្វា អឌ្ឍយោសំ    តត្ថ នេសំ អគារកំ**
**យត្ថ មាតាបិតា មយ្ហំ    តេ ភរស្សុ ឥតោ គតោ។**

បពិត្រមហារាជសូមទតឱ្យជាក់    ផ្លូវចុះជើងម្នាក់ទិសក្បាលដំណេក
នៃទូលបង្គំជាខ្ញុំដែលដេក    មិនជាឆ្ងាយពេកកន្លះឃោសៈ ។

ស្តេចយាងទៅឃើញបណ្ណសាលា មាតាបិតាឋិតក្នុងសម្នាក់
សូមទ្រង់អនុគ្រោះដោយក្តីស្នោះស្នេហ៍ សូមទ្រង់ភារៈចិញ្ចឹមលោកផង ។

បណ្តាបទទាំងនោះ បទថា **ឯកបទី** ប្រែថា ផ្លូវដើរបានចំពោះតែម្នាក់ ។

បទថា **ឧស្សីសកេ** បានដល់ ក្នុងទិសខាងសីសៈនៃខ្ញុំព្រះអង្គនេះ ។

បទថា **អឡ្ហឃោសំ** ប្រែថា រវាងកន្លះសំឡេងស្រែកហៅ ។

ព្រះពោធិសត្វ បានទូលប្រាប់ផ្លូវដល់ព្រះរាជាយ៉ាងនេះហើយ ខំអត់ទ្រាំនឹងទុក្ខវេទនាដែលមានសភាពបែបនោះ ទុកដោយសិនេហចិត្ត ក្នុងមាតាបិតាជាកម្លាំង ហើយប្រណម្យអញ្ជលីទូលអង្វរក្នុងបំណងត្រូវការ សូមឱ្យព្រះរាជាចិញ្ចឹមមាតាបិតា បានទូលយ៉ាងនេះទៀតថា :

**នមោ តេ កាសិរាជត្ថុ នមោ តេ កាសិវឌ្ឍន**
**អន្ធា មាតាបិតា មយ្ហំ តេ ភរស្សុ ព្រហាវនេ។**



បពិត្រមហារាជគ្រងដែនកាសី ទ្រង់មានសេចក្តីចម្រើនកន្លង
ខ្ញុំសាមសូមថ្វាយបង្គំស្តេចផង នមោច្រើនដងបង្គំរាជា ។
មាតាបិតានៃទូលបង្គំ នៅក្នុងព្រៃធំអន្ធោអន្ធា
សូមទ្រង់ចិញ្ចឹមឱ្យមានជន្មា នៅជាតាបសតបស្សិនី ។

**អញ្ជលិន្តេ បគ្គណ្ហាមិ កាសិរាជ នមត្ថុ តេ**
**មាតរំ បិតរំ មយ្ហំ វុត្តោ វជ្ជាសិ វន្ទនំ ។**

ទូលបង្គំជាខ្ញុំសូមផ្គងអញ្ជលី រាជាគ្រងទីនាដែនកាសី
ទូលបង្គំសូមពរស្តេចទ្រង់ប្រណី នាំយកសេចក្តីនៃខ្ញុំព្រះអង្គ ។
ខ្ញុំសូមបង្គំមាតាបិតា ឱនក្រាបសិរសាផ្តាំផ្ញើតាមទ្រង់
សាមត្រូវព្រួញពិសបានជាបាត់អង្គ ដួលដេកនៅត្រង់ឆ្នេរខ្សាច់មាត់ស្ទឹង។

បណ្តាបទទាំងនោះ បទថា **វុត្តោ វជ្ជាសិ** ដោយសេចក្តីថា ព្រះពោធិសត្វទូលថា : បពិត្រព្រះរាជាដ៏ជាធំ ទ្រង់ដែលខ្ញុំព្រះអង្គក្រាបទូលហើយ សូមទ្រង់មេត្តាប្រោសត្រាស់ប្រាប់ការក្រាបថ្វាយបង្គំ ឱ្យមាតាបិតាបានជ្រាបយ៉ាងនេះថា សាមបុត្ររបស់លោកទាំងពីរ ត្រូវយើងបាញ់ដោយព្រួញពិសក្បែរមាត់ស្ទឹង ដេកផ្ទៀងខាងស្តាំ នៅនឹងឆ្នេរខ្សាច់ពណ៌ដូចផែនប្រាក់ ផ្គងអញ្ជលីដល់លោក ក្រាប-

ថ្វាយបង្គំជើងទាំងពីររបស់លោក ។

ព្រះរាជាទ្រង់ទទួលពាក្យនៃព្រះពោធិសត្វ ។ ឯចំណែកព្រះពោធិសត្វ កាលបានធ្វើនូវការថ្វាយបង្គំចំពោះមាតាបិតារួចហើយ ក៏ដល់នូវវិសញ្ញីសន្លប់ស្មៀមទៅ ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់ប្រកាសនូវសេចក្តីនោះ ទើបត្រាស់ថា :

**ឥទំ វត្វាន សោ សាមោ យុវា កល្យាណទស្សនោ**
**មុច្ឆិតោ វិសវេគេន វិសញ្ញី សមបជ្ជថ ។**

កំលោះសាម ជាអ្នកមានរូបល្អ គួរឱ្យពិតពិលរមិលមើលនោះ លុះពោលនូវពាក្យនេះរួចហើយ ក៏ជ្រប់សន្លប់ដោយកម្លាំងពិស ។

បណ្តាបទទាំងនោះ បទថា **សមបជ្ជថ** បានដល់ជាបុគ្គលវិសញ្ញី ។

ព្រះពោធិសត្វនោះ កាលដែលពោលបានមកត្រឹមតែប៉ុណ្ណេះ ក៏រលត់អស្សាសៈ មិនបានពោលតទៅទៀតឡើយ ក៏ក្នុងកាលនោះ ពាក្យដែលប្រព្រឹត្តទៅ អាស្រ័យ



ហទយរូប មានចិត្តជាសមុដ្ឋាន របស់ព្រះពោធិសត្វនោះបានដាច់ហើយ ព្រោះកម្លាំងនៃពិសជ្រួតជ្រាប ។ មាត់របស់ព្រះពោធិសត្វក៏បិទ ចក្ខុក៏បិទ ដៃជើងឡើងរឹង និងរាងកាយទាំងអស់ប្រឡាក់ទៅដោយលោហិត ។

លំដាប់នោះ ព្រះរាជាទ្រង់គិតថា សាមនេះនិយាយជាមួយយើង ឥឡូវនេះ តើដូចម្តេចទៅហើយហ្ន៎ ទើបទ្រង់ពិចារណាត្រួតមើលខ្យល់អស្សាសៈ បស្សាសៈរបស់ព្រះពោធិសត្វ ឃើញថាអស្សាសៈ និងបស្សាសៈរលត់ទៅហើយ សរីរៈក៏រឹងហើយដែរ ។ ព្រះរាជាទ្រង់ទតព្រះនេត្រឃើញហេតុនោះ ទ្រង់ក៏ជ្រាបថា ឥឡូវនេះសាមស្លាប់ហើយ ។ ទ្រង់មិនអាចអត់ទ្រាំនូវសេចក្តីសោកទុកបាន ក៏ដាក់ព្រះហស្តលើព្រះសីសៈ ទ្រង់ព្រះកន្សែងរៀបរាប់ដោយសំឡេងខ្លាំងៗ ។

ព្រះបរមសាស្តា កាលដែលទ្រង់ប្រកាសនូវសេចក្តីនោះទើបត្រាស់ថា :

ស រាជា បរិទេវេសិ ពហុំ ការុញ្ញសញ្ហិតំ
អជរាមរោហំ អាសឹ អជ្ជេតំ ញ្ញាមិ នោ បុរេ
សាមំ កាលកតំ ទិស្វា នត្ថិ មច្ចុស្ស នាគមោ ។

ព្រះរាជាអង្គនោះ ទ្រង់ព្រះកន្សែងរៀបរាប់ នូវពាក្យដែលប្រកបដោយសេចក្តីករុណា មានប្រមាណច្រើនថា : អាត្មាអញបានយល់ថា អញមិនចាស់មិនស្លាប់ ។ ថ្ងៃនេះ យើងបានឃើញសាមបណ្ឌិតធ្វើកាលកិរិយា ដែលមិនធ្លាប់បានដឹងពីមុនមក ឥឡូវទើបដឹងថា ការមិនមកនៃមច្ចុរមែងមិនមាន ។

យស្សុ មំ បដិមន្តេតិ សវិសេន សមប្បិតោ
ស្វាជ្ជេវង្គតេ កាលេ ន កិញ្ចិមភិភាសតិ ។

សាមបណ្ឌិត ដែលត្រូវថ្នាំពិសជ្រួតជ្រាប កំពុងចរចាជាមួយនឹងអាត្មាអញ (ក្នុងកាលអម្បាញ់មិញនេះ ) ឥឡូវនេះ សាមលែងនិយាយពាក្យតិចតួច ក្នុងកាលប្រព្រឹត្តទៅ យ៉ាងនេះក្នុងថ្ងៃនេះហើយ ។



និរយំ នូន គច្ឆាមិ ឯត្ថ មេ នត្ថិ សំសយោ
តទា ហិ បកតំ បាបំ ចិរំ រត្តាយ កិព្ពិសំ ។

អាត្មាអញប្រាកដជានឹងទៅកាន់នរកពុំខាន អាត្មាអញឥតមានសេចក្តីសង្ស័យ ក្នុងដំណើរនេះទេ ព្រោះថាអំពើបាបដែលអាត្មាអញ ធ្វើទុកហើយក្នុងគ្រានោះ នឹងជាទោសឱ្យផលដ៏អាក្រក់ អស់រាត្រីកាលជាអង្វែង ។

ភវន្តិ តស្ស វត្តារោ គាមេ កិព្ពិសការកោ
អរញ្ញេ និម្មនុស្សម្ហិ កោ មំ វត្តុមរហតិ ។

បើនៅក្នុងស្រុកគង់មានពួកអ្នកតិះដៀល អាត្មាអញនោះថា ព្រះអង្គជាអ្នកធ្វើអំពើអាក្រក់ដូច្នេះ តែ ក្នុងអរញ្ញប្រទេស ដែលឥតមនុស្ស តើនរណាតិះដៀលអាត្មាអញបាន ។

សារយន្តិ ហិ កម្មានិ គាមេ សង្គច្ច មាណវា
អរញ្ញេ និម្មនុស្សម្ហិ កោ នុ មំ សារយិស្សតិ។

បើនៅក្នុងស្រុក ពួកមាណពប្រជុំគ្នា ហើយចោទប្រកាន់នូវអំពើទាំងឡាយរបស់អាត្មាអញ តែក្នុងអរញ្ញ-

ប្រទេសដែលឥតមនុស្ស តើនរណានឹងចោទប្រកាន់អាត្មាអញបាន ។

បណ្ដាបទទាំងនោះ បទថា **អាសឹ** ដោយសេចក្ដីថា យើងមានសេចក្ដីសំគាល់ថា នឹងមិនចាស់មិនស្លាប់មករហូតកាលប៉ុណ្ណេះ ។

បទថា **អជ្ជេតំ** ដោយសេចក្ដីថា ថ្ងៃនេះយើងបានឃើញសាមបណ្ឌិតនេះធ្វើកាលកិរិយា ទើបដឹងថា ទាំងខ្លួនយើងនិងពួកសត្វដទៃៗ ត្រូវចាស់ ត្រូវស្លាប់ទាំងអស់។

បទថា **នត្ថិ មច្ចុស្ស នាគមោ** ដោយសេចក្ដីថា ព្រះរាជាទ្រង់ព្រះកន្សែងពិលាបថា ការមកនៃមច្ចុនោះ យើងដឹងក្នុងថ្ងៃនេះឯង ក្នុងកាលមុននេះ យើងមិនបានដឹងឡើយ ។

បទថា **ស្វាជ្ជេវខន្ធតេ កាលេ** ដោយសេចក្ដីថា ព្រះរាជាទ្រង់សម្ដែងថា សាមបណ្ឌិតណា ត្រូវពិសនៃព្រួញជ្រួតជ្រាបហើយ ចរចាជាមួយនឹងយើងក្នុងកាលនេះ សាមបណ្ឌិតនោះ ដល់នូវមរណភាព ប្រព្រឹត្តទៅយ៉ាងនេះ



ក្នុងថ្ងៃនេះ មិនពោលអ្វីៗឡើយ សូម្បីតែបន្តិច ។

បទថា **តទា ហិ** ដោយសេចក្ដីថា យើងជាអ្នកបាញ់សាមបណ្ឌិត ក្នុងខណៈនោះ បានធ្វើបាបហើយ ។

បទថា **ចិរំ រត្តាយ កិព្វិសំ** ដោយសេចក្ដីថា ក៏បាបនោះ ជាអំពើដ៏ទារុណអាក្រក់លាមក អាចធ្វើឱ្យក្ដៅក្រហាយអស់រាត្រីកាលជាអង្វែង ។

បទថា **តស្ស** ដោយសេចក្ដីថា តិះដៀលយើងនោះ ដែលជាអ្នកធ្វើកម្មអាក្រក់មានសភាពបែបនេះ ។

បទថា **វត្តារោ** ដោយសេចក្ដីថា រមែងតិះដៀល។ តិះដៀលទីណា ? តិះដៀលក្នុងស្រុក ។ តិះដៀលថាដូចម្ដេច ? តិះដៀលថា ជាអ្នកធ្វើអំពើអាក្រក់លាមក ។

ព្រះរាជាទ្រង់ព្រះកន្សែងថា : ក៏ក្នុងព្រៃដែលរកមនុស្សមិនមាននេះ នរណាហ្ន៎ គួរនឹងពោលតិះដៀលយើង បើថាមាន គប្បីតិះដៀលមកចុះ ។

បទថា **សារយន្តិ** បានដល់ក្នុងភូមិ ឬក្នុងនិគមជាដើម ។

បទថា **សង្គច្ឆ មាណវា** ដោយសេចក្តីថា មនុស្សទាំងឡាយនឹងប្រជុំគ្នាក្នុងទីនោះៗ នឹងញុំាងគ្នានឹងគ្នាឱ្យរលឹកដល់កម្មទាំងឡាយ ហើយចោទយ៉ាងនេះថា នែ អ្នកឯងជាអ្នកសម្លាប់មនុស្ស អ្នកបានធ្វើនូវទារុណកម្ម អ្នកនឹងត្រូវបានទទួលទោសយ៉ាងនោះ តែនៅក្នុងព្រៃដែលមិនមានមនុស្សនេះ អ្នកណានឹងញុំាងព្រះរាជានេះ ឱ្យរលឹកដល់កម្ម ។ ព្រះរាជាទ្រង់ចោទខ្លួនព្រះអង្គឯង ទ្រង់ព្រះកន្សែងយ៉ាងនេះ ដោយប្រការដូច្នេះឯង ។

កាលនោះ ទេពធីតាមាននាមថា **ពសុន្ធរី** នៅភ្នំគន្ធមាទន៍ ធ្លាប់ជាមាតារបស់ព្រះពោធិសត្វ ក្នុងអត្តភាពទី ៧ តែងតែពិចារណាមើលព្រះពោធិសត្វជានិច្ច ដោយសេចក្តីស្នេហាក្នុងបុត្រ ។ ក្នុងថ្ងៃនោះនាងសោយទិព្វ-សម្បត្តិ មិនបានពិចារណាមើលព្រះពោធិសត្វ[១] ។ ក្នុងពេលដែលព្រះពោធិសត្វសន្លប់ នាងពិចារណាមើលថា ការប្រព្រឹត្តទៅនៃបុត្ររបស់យើង យ៉ាងដូចម្តេចដែរហ្ន៎ ក៏

១.អាចារ្យពួកខ្លះ ពោលថា នាងទៅកាន់ទេវសមាគម ។



បានឃើញថា ព្រះបាទបិលយក្ខនេះ បាញ់បុត្ររបស់យើង ដោយព្រួញពិស ឱ្យដួលចុះនៅនឹងផ្ទៃរខ្សាច់ មាត់ស្ទឹងមិគសម្មតា ។ ទេពធីតាដឹងដូច្នេះហើយ ក៏បានស្រែកយំមួយរំពេច ដោយសំឡេងខ្លាំងៗ ហើយក៏បានពិចារណាឃើញដូច្នេះទៀតថា បើយើងមិនទៅទីនោះទេ សុវណ្ណ-សាមបុត្ររបស់យើង នឹងវិនាសក្នុងទីនោះឯង សូម្បីព្រះហឫទ័យនៃព្រះរាជា ក៏នឹងបែកធ្លាយ ឯចំណែកមាតាបិតារបស់សុវណ្ណសាមនឹងអត់អាហារ អត់ទឹក ហើយនឹងត្រូវបាត់បង់ជីវិត ។ ប៉ុន្តែកាលដែលយើងទៅ ព្រះរាជានឹងកាន់យកក្អមទឹកទៅកាន់សម្នាក់នៃមាតាបិតារបស់សុវណ្ណ-សាមនោះ លុះគ្រាដែលស្តេចយាងទៅដល់ហើយ នឹងប្រាប់ថា បុត្ររបស់អ្នកទាំងពីរ យើងសម្លាប់ហើយ និងកាលដែល ព្រះរាជាទ្រង់ព្រះសណ្តាប់នូវពាក្យរបស់អ្នកទាំងពីរនោះហើយ ទ្រង់នឹងនាំនូវអ្នកទាំងពីរនោះទៅកាន់ទីដែលសុវណ្ណសាមកំពុងសន្លប់ កាលបើដូច្នោះ តាបសតាបសី ទាំងពីរ ព្រមទាំងយើង នឹងធ្វើនូវសច្ចកិរិយា ពិស

របស់សុវណ្ណសាមក៏នឹងវិនាសបាត់អស់ បុត្ររបស់យើងនឹងបានជីវិតត្រឡប់មកវិញ ចំណែកភ្នែកទាំងពីររបស់មាតានិងរបស់បិតានៃសុវណ្ណសាម ក៏នឹងបានមើលឃើញជាប្រក្រតីវិញដែរ ។ ម្យ៉ាងវិញទៀត ព្រះរាជាទ្រង់នឹងបានព្រះសណ្តាប់នូវព្រះធម៌ទេសនារបស់សុវណ្ណសាម ស្តេចយាងត្រឡប់ទៅព្រះនគរវិញ ទ្រង់នឹងបរិច្ចាគមហាទាន គ្រងរាជសម្បត្តិដោយយុត្តិធម៌ មានសុគតិភពប្រព្រឹត្តទៅខាងមុខ ព្រោះហេតុនោះ យើងនឹងទៅក្នុងទីនោះ ។

ទេពធីតានោះឯង បានយាងទៅស្ថិតនៅឰដ៏-អាកាស ដោយមិនប្រាកដកាយ នាមាត់ស្ទឹងមិគសម្មតា ហើយបានពោលទៅកាន់ព្រះបាទបិលយក្ខ ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់ប្រកាសនូវសេចក្តីនោះ ទើបត្រាស់ថា :

**សា ទេវតា អន្តរហិតា បព្វតេ គន្ធមាទនេ**
**រញ្ញោវ អនុកម្បាយ ឥមា គាថា អភាសថ ។**

ទេវតានោះ បាត់អំពីភ្នំគន្ធមាទន៍ ហើយពោលនូវ



គាថាទាំងឡាយនេះ ដោយអនុគ្រោះព្រះរាជាថា :

**អាគុំ កិរ មហារាជ អករិ កម្មទុក្កដំ**
**អទូសកា បិតាបុត្តា តយោ ឯកូសុនា ហតា ។**

បពិត្រមហារាជ ព្រះអង្គទ្រង់បានធ្វើនូវបាបជាទម្ងន់ ដែលជាអំពើអាក្រក់ ជនទាំងបីនាក់ គឺមាតាបិតានិងបុត្រ ជាអ្នកមិនប្រទូស្ត ទ្រង់បានសម្លាប់ហើយដោយព្រួញតែមួយ ។

**ឯហិ តំ អនុសិក្ខាមិ យថា តេ សុគតី សិយា**
**ធម្មេនន្ធេ វនេ បោស មញ្ញេហំ សុគតី សិយា ។**

សូមទ្រង់មក សុគតិភពនឹងគប្បីមានដល់ព្រះអង្គយ៉ាងណា ខ្ញុំនឹងពន្យល់ព្រះអង្គយ៉ាងនោះ សូមទ្រង់ចិញ្ចឹមនូវជនដែលងងឹតភ្នែកទាំងពីរនាក់នោះឯងដោយធម៌ ខ្ញុំ-ម្ចាស់យល់ថា សុគតិភពនឹងគប្បីមានដល់ព្រះអង្គ ។

បណ្តាបទទាំងនោះ បទថា **រញ្ញោវ** ប្រែថា ព្រះ-រាជានោះឯង ។

បទថា **អាគុំ កិរ** ដោយសេចក្តីថា បពិត្រព្រះរាជា

ដ៏ជាធំ ព្រះអង្គទ្រង់បានធ្វើនូវកំហុសច្រើនគឺបាបច្រើន ។

បទថា **ទុក្កដំ** ដោយសេចក្តីថា សេចក្តីអាក្រក់នោះគឺជាកម្មដ៏លាមក ។

បទថា **អនូសភា** ប្រែថា បុគ្គលដែលរកទោសមិនបាន ។

បទថា **បិតាបុត្តា** ដោយសេចក្តីថា មនុស្ស ៣ នាក់នេះគឺ មាតា ១ បិតា ១ និងបុត្រ ១ ព្រះអង្គសម្លាប់ដោយព្រួញតែមួយ ព្រោះថា កាលដែលព្រះអង្គទ្រង់សម្លាប់នូវសុវណ្ណសាមនោះ សូម្បីមាតាបិតារបស់សុវណ្ណ-សាម ដែលជាអ្នកមានប្រតិព័ទ្ធជាមួយនឹងសុវណ្ណសាមនោះ រមែងជាបុគ្គលដែលព្រះអង្គទ្រង់សម្លាប់ដូចគ្នាដែរ។

បទថា **អនុសិក្ខាមិ** ដោយសេចក្តីថា នឹងឱ្យសិក្សាគឺពន្យល់ ។

បទថា **ឃោស** ដោយសេចក្តីថា ចូរតាំងនៅក្នុងថានៈសុវណ្ណសាម ចូរញ៉ាំងសេចក្តីស្នេហាឱ្យកើតឡើងចិញ្ចឹមបីបាច់ថែរក្សានូវមាតាបិតាទាំងពីរ ដែលងងឹតភ្នែក



នោះ ប្រហែលគ្នានឹងសុវណ្ណសាមដែរ ។

បទថា **មញ្ញេហំ សុគតឹ សិយា** ដោយសេចក្តីថា ខ្ញុំម្ចាស់យល់ថា ព្រះអង្គនឹងគប្បីទៅកាន់សុគតិភពតែម៉្យាងប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ។

ព្រះរាជាទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ទេពធីតាហើយ ទ្រង់ជឿថា យើងចិញ្ចឹមមាតាបិតារបស់សុវណ្ណ-សាមហើយ នឹងទៅកាន់ស្ថានសួគ៌ ។ ទ្រង់មាននូវព្រះតម្រិះថា យើងនឹងត្រូវការរាជសម្បត្តិធ្វើអ្វី យើងនឹងចិញ្ចឹមបីបាច់ថែរក្សានូវលោកទាំងពីរនោះ។ ទ្រង់បានតាំងព្រះហឫទ័យមាំ ទ្រង់មានការយំសោកស្តាយដ៏ក្រៃលែងលុះទ្រង់ធ្វើនូវសេចក្តីសោកឱ្យស្រាលស្តើងហើយ ទាំងដែលទ្រង់យល់នៅក្នុងព្រះហឫទ័យថា សុវណ្ណសាមព្រះ-ពោធិសត្វអស់ជីវិតហើយ ទើបទ្រង់បូជាសរីរៈរបស់ព្រះ-ពោធិសត្វនោះ ដោយបុប្ផជាតិផ្សេងៗ ប្រោះព្រំដោយទឹកធ្វើប្រទក្សិណបីជុំ ទ្រង់ក្រាបក្នុងកន្លែងទាំងបួនហើយ ក៏កាន់ក្អមទឹកដែលព្រះពោធិសត្វដងមកពេញហើយ ដល់នូវ

សេចក្ដីទោមនស្ស បែរព្រះភក្ត្រទៅទិសទក្សិណ ស្ដេចយាងចេញទៅ ។

ព្រះបរមសាស្ដា កាលដែលព្រះអង្គទ្រង់ប្រកាសនូវសេចក្ដីនោះ ទើបត្រាស់ថា :

**ស រាជា បរិទេវិត្វា ពហុំ ការុញ្ញសញ្ហិតំ**
**ឧទកកុម្ភមាទាយ បក្កាមិ ទក្ខិណាមុខោ ។**

ព្រះរាជាអង្គនោះ ទ្រង់ពិលាបរៀបរាប់ ប្រកបដោយសេចក្ដីករុណា មានប្រមាណច្រើន ហើយកណ្ដៀតក្អមទឹក យាងឆ្ពោះទៅទិសទក្សិណ ។

ដោយប្រក្រតី ព្រះរាជាគឺជាអ្នកមានកម្លាំងច្រើន ទ្រង់កណ្ដៀតក្អមទឹកចូលទៅកាន់អាស្រមបទ ដល់ខ្លោងទ្វារបណ្ណសាលានៃទុកូលបណ្ឌិត ក៏ដូចជាបុគ្គលចាប់អង្រួនអាស្រមឱ្យញ័រ ។ ទុកូលបណ្ឌិត អង្គុយនៅខាងក្នុងបានស្ដាប់សំឡេងនៃដំណើរព្រះបាទរបស់ស្ដេចបិលយក្ខ ក៏នឹកក្នុងចិត្តថា នេះមិនមែនជាសំឡេងជើងដើររបស់សុវណ្ណ-សាមបុត្រយើងឡើយ ស្នូរជើងដើររបស់អ្នកណាទៅហ្ន៎ ។



កាលដែលនឹងសួរទើបពោលនូវគាថា :

**កស្ស នុ ឯសោ បទសទ្ទោ មនុស្សស្សេវ អាគតោ**
**នេសោ សាមស្ស និគ្ឃោសោ កោ នុ ត្វមសិ មារិស ។**

សូរជើងអ្វីហ្នឹងដើរមកនោះហ្ន៎ ឮសូរឮដ៏ពិតជាមនុស្សា
តែមិនមែនសូរជើងសាមកុមារ តើជានរណាម្នាលអ្នកនិរទុក្ខ ។

**សន្តំ ហិ សាមោ វជតិ សន្តំ បាទានិ នេយតិ**
**នេសោ សាមស្ស និគ្ឃោសោ កោ នុ ត្វមសិ មារិស ។**

ដ្បិតសាមជើងស្រាលលើកដាក់ថ្នមៗ ឮសូរតិចល្មមមិនមែនគំហុក
សូរនោះមិនមែនសាមមាសឪពុក ម្នាលអ្នកនិរទុក្ខអ្នកជាអ្វីហ្នឹង ។

បណ្ដាបទទាំងនោះ បទថា **មនុស្សស្សេវ** ដោយសេចក្ដីថា សំឡេងជើងដើរមកនេះ មិនមែនជាសំឡេងជើងរាជសីហ៍ ខ្លាធំ ខ្លាដំបង យក្ស ឬកិន្នរជាដើមឡើយ គឺជាសូរជើងរបស់មនុស្សដោយពិត ប៉ុន្តែមិនមែនជាសុវណ្ណសាមទេ ។

បទថា **សន្តំ ហិ** បានដល់ ស្រាលៗ ស្ងាត់ៗ ។

បទថា **វជតិ** បានដល់ ឈានទៅ ។

ព្រះរាជាបានស្តាប់ពាក្យសួរនោះហើយ ទ្រង់ព្រះតម្រិះថា បើយើងមិនប្រាប់នូវភាពដែលយើងជាព្រះរាជាទេ ប្រាប់ថាយើងសម្លាប់បុត្ររបស់អ្នកហើយ លោកទាំងពីរនាក់នេះនឹងក្រោធជាមួយយើង ហើយពោលពាក្យទ្រគោះបោះបោកមករកយើង កាលបើដូច្នេះ យើងក៏មានសេចក្តីក្រោធតបទៅរកអ្នកទាំងពីរវិញ កាលដែលយើងក្រោធហើយ យើងនឹងបៀតបៀនដល់អ្នកទាំងពីរនោះកម្មនោះនឹងជាអកុសលរបស់យើង ប៉ុន្តែកាលបើយើងប្រាប់ថា យើងជាព្រះរាជា ឈ្មោះថា អ្នកដែលមិនខ្លាចក្រែងរមែងមិនមាន ព្រោះដូច្នោះ យើងនឹងប្រាប់នូវភាពដែលយើងជាព្រះរាជាមុន ។ ទ្រង់ព្រះតម្រិះដូច្នេះហើយទ្រង់ក៏ដាក់ក្អមទឹកទុកនៅនឹងរោងទឹក ហើយប្រថាប់ឈរនៅនឹងទ្វារបណ្ណសាលា ។ កាលដែលនឹងសម្តែងព្រះអង្គឱ្យឥសីស្គាល់ ទើបត្រាស់ថា :

**រាជាហមស្មិ កាសីនំ    បិលយក្ខោតិ មំ វិទូ**
**លោភា រដ្ឋំ បហិត្វាន    មិគមេសំ ចរាមហំ ។**



គេស្គាល់ឈ្មោះខ្ញុំថាបិលយក្ខ    ជាស្តេចនៃអ្នកក្នុងដែនកាសី
ខ្ញុំលះបង់ដែនស្វែងរកម្រឹគព្រៃ    ព្រោះលោភនឹងឆីសោយរសមំសំ ។

**ឥស្សត្ថេ ចស្មិ កុសលោ    ទឡ្ហធម្មោតិ វិស្សុតោ**
**នាគោបិ មេ ន មុញ្ចេយ្យ    អាគតោ ឧសុបាតនំ ។**

ម្យ៉ាងទៀតខ្ញុំល្បីវៃខាងសិល្បសាស្ត្រ ធ្នូសរខ្ញុំច្បាស់បាញ់ពេញកម្លាំង
សត្វណាមកចំមុខព្រួញខ្ញុំតាំង    ទោះដំរីខ្លាំងមិនរួចឡើយណា ។

ចំណែកទុកូលបណ្ឌិត កាលដែលនឹងធ្វើនូវបដិសណ្ឋារៈ ជាមួយនឹងព្រះរាជា ទើបទូលថា :

**ស្វាគតន្តេ មហារាជ    អថោ តេ អទុរាគតំ**
**ឥស្សរោសិ អនុប្បត្តោ    យំ ឥធត្ថិ បវេទយ ។**

បពិត្រមហារាជយាងមកល្អហើយ ពុំអាក្រក់ឡើយស្តេចយាងមកដល់
សូមទ្រង់ឥស្សរៈជ្រាបផលាផល    អ្វីណាតម្កល់មានក្នុងទីនេះ ។

**តិណ្ឌុកានិ បិយាលានិ    មធុកេ កាសមារិយោ**
**ផលានិ ខុទ្ទកប្បានិ    ភុញ្ជ រាជ វរំ វរំ ។**

ទន្លាប់មាក់ប៉ែននិងផ្លែស្រគំ    ផ្អែមដូចទឹកឃ្មុំតូចធំវិសេស
នៅទីតែមួយសូមព្រះតម្រិះ    សោយផ្លែទាំងនេះរសសុទ្ធប្រសើរ ។

**ឥតម្បិ បានីយំ សីតំ    អាគតំ គិរិគព្ភរា**
**ឥតោ បិវ មហារាជ    សចេ ត្វំ អភិកង្ខសិ ។**

នេះទឹកត្រជាក់ដងពីជ្រោះភ្នំ    មហារាជជាធំគឺប្រសិនបើ
ទ្រង់សព្វហឫទ័យទឹកជ្រោះប្រសើរ ដងតាមដំណើរពីនេះសោយចុះ ។

បណ្តាបទទាំងនោះ បទថា **គិរិគព្ភរា** លោកពោលសំដៅយកមិគសម្មតានទី ព្រោះមិគសម្មតានទីនោះ ហូរមកអំពីជ្រោះភ្នំ ទើបឈ្មោះថា កើតអំពីជ្រោះភ្នំ ។

កាលដែលទុកូលតាបស ធ្វើបដិសណ្ឋារៈយ៉ាងនេះហើយ ព្រះរាជាទ្រង់ព្រះតម្រិះថា យើងមិនគួរនឹងប្រាប់ថា យើងបានសម្លាប់បុត្ររបស់លោកហើយនោះទេ ធ្វើដូចជាមិនដឹង និយាយរឿងអ្វីៗជាមុនសិនសឹមប្រាប់ ទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបត្រាស់ថា :

**នាឡំ អន្ធា វនេ ទដ្ឋុំ    កោ នុ ខោ ផលមាហរិ**
**អនន្ធស្សេវាយំ សម្មា    និវាបោ មយ្ហ ខាយតិ ។**

សុទ្ធអ្នកងងឹតមិនឃើញព្រឹក្សព្រៃ    ចុះនរណានៃនាំផលដល់អ្នក
ចំណីប្រពៃរៀបចំល្អជាក់    ហាក់ដូចជាអ្នកមិនខ្វាក់ភ្នែកឡើយ ។



បណ្តាបទទាំងនោះ បទថា **នាឡំ** ដោយសេចក្តីថា អ្នកទាំងពីរងងឹតភ្នែក មិនអាចនឹងមើលឃើញអ្វីៗ ក្នុងព្រៃនេះបាន ។

បទថា **កោ នុ ខោ ផលមាហរិ** ដោយសេចក្តីថា នរណាហ្ន៎នាំផ្លែឈើតូចធំ មកដើម្បីលោកទាំងពីរ ។

បទថា **និវាបោ** ដោយសេចក្តីថា ការទុកដាក់គឺសន្សំនូវផ្លែឈើតូចធំដែលបរិសុទ្ធល្អ គួរដល់ការទទួលទានដែលធ្វើទុកយ៉ាងរៀបរយ គឺដោយន័យ ដោយឧបាយដោយហេតុនេះ ។

បទថា **អនន្ធស្សេវ** ដោយសេចក្តីថា រមែងប្រាកដគឺចូលទៅតាំងទុកក្នុងចិត្តរបស់យើងថា ដូចជាមនុស្សដែលមានភ្នែកល្អជាអ្នករៀបចំទុកដាក់ ។

ទុកូលបណ្ឌិត បានស្តាប់ដូច្នោះហើយ ដើម្បីនឹងសម្តែងថា មូលផលាផលគឺខ្លួនមិនបាននាំមកទេ តែបុត្ររបស់ខ្លួននាំមក ទើបបានពោល ២ គាថាថា :

**ឧហរោ យុវា នាតិព្រហា សាមោ កល្យាណទស្សនោ**
**ទីឃស្ស កេសា អសិតា អថោ សុនគ្គវេល្លិតា ។**
**សោ ហវេ ផលមាហរិត្វា ឥតោ អាទាយ កមណ្ឌលុំ**
**នទិំ គតោ ឧទហារោ មញ្ញេ ន ទូរមាគតោ ។**

សាមនៅកំលោះមិនខ្ពស់មិនទាប ឫកពាសុភាពរូបល្អគន់គាប់
សក់វែងងចុងខ្មៅរលើបសព្វ សាមមានគុណគាប់ជាប់ចិត្តម៉ែឪ ។
សាមរកបានផ្លែតូចធំរដឹក សាមកាន់ក្អមទឹកពីទីនេះទៅ
ឆ្ពោះត្រង់នទីរហូតឥឡូវ ប្រហែលជាត្រូវមកជិតដល់ហើយ ។

បណ្ដាបទទាំងនោះ បទថា **នាតិព្រហា** ដោយសេចក្ដីថា មិនខ្ពស់ពេក មិនទាបពេក ។

បទថា **សុនគ្គវេល្លិតា** ដោយសេចក្ដីថា មានចុងងទៅខាងលើ ។

បទថា **កមណ្ឌលុំ** បានដល់ក្អម ។

បទថា **ទូរមាគតោ** ដោយសេចក្ដីថា យល់ថាឥឡូវនេះកូនសាមមកជិតហើយ គឺមកហើយកាន់ទីជិត ។

ព្រះរាជាទ្រង់បានព្រះសណ្ដាប់ដូច្នោះហើយ ទើប



ត្រាស់ថា :

**អហន្តំ អវធិំ សាមំ យោ តុយ្ហំ បរិចារិកោ**
**យំ កុមារំ បវេទេថ សាមំ កល្យាណទស្សនំ ។**
**ទីឃស្ស កេសា អសិតា អថោ សុនគ្គវេល្លិតា**
**តេសុ លោហិតលិត្តេសុ សេតិ សាមោ មយាហតោ ។**

អ្នកពោលសំដៅកុមារសាមណា ដែលសាមនោះរ៉ារូបល្អគន់គាប់
សក់វែងងចុងខ្មៅរលើបសព្វ សាមមានគុណគាប់បម្រើម៉ែឪ ។
ខ្ញុំបានសម្លាប់សាមនោះទៅហើយ សាមមិនមកឡើយដួលនៅនឹងផ្លូវ
ដេកលើឆ្អេរខ្សាច់ខ្លួនប្រាណហ្មងសៅ ឈាមក្រហមឆ្អៅប្រឡាក់កាយា ។

បណ្ដាបទទាំងនោះ បទថា **អវធិំ** ដោយសេចក្ដីថា ខ្ញុំបាញ់ដោយព្រួញសម្រាប់បាញ់ម្រឹគ ឱ្យស្លាប់ហើយ ។

បទថា **បវេទេថ** បានដល់ ពោលដល់ ។

បទថា **សេតិ** ដោយសេចក្ដីថា ដេកនៅលើឆ្នេរខ្សាច់មាត់ច្រាំងមិគសម្មតានទី ។

ក៏បណ្ណសាលារបស់ចារិកាតបស្សិនី នៅជិតបណ្ណសាលានៃទុកូលបណ្ឌិត ។ នាងអង្គុយនៅក្នុងបណ្ណសាលា

នោះ បានស្តាប់ព្រះតម្រាស់របស់ព្រះរាជា ប្រាថ្នានឹងដឹងនូវព្រឹត្តិការណ៍នោះ ទើបចេញចាកពីបណ្ណសាលារបស់ខ្លួន ទៅកាន់សម្នាក់របស់ទុកូលបណ្ឌិត តាមខ្សែដែលសាមចងសម្រាប់ដើរ ហើយបានពោលថា :

**កេន ទុកូល មន្តេសិ ហតោ សាមោតិ វាទិនា**
**ហតោ សាមោតិ សុត្វាន ហទយំ មេ បវេធតិ ។**
**អស្សត្ថស្សេវ តរុណំ បវាឡំ មាលុតេរិតំ**
**ហតោ សាមោតិ សុត្វាន ហទយំ មេ បវេធតិ ។**

ទុកូលប្រឹក្សាជាមួយអ្នកណា ថាសាមនោះវ៉ាខ្ញុំបានសម្លាប់
បេះដូងខ្ញុំញ័រព្រោះឮពាក្យប្រាប់ ថាខ្ញុំសម្លាប់សាមនោះទៅហើយ ។
ហឫទ័យខ្ញុំញ័រដូចត្រួយពោធិ៍បាយ ស្លឹកខ្ចីទាំងឡាយមិនស្ងប់ស្ងៀមឡើយ
ព្រោះត្រូវខ្យល់បក់ទុក្ខខ្ញុំពុំស្បើយ ព្រោះបានឮហើយសាមត្រូវសម្លាប់ ។

បណ្តាបទទាំងនោះ បទថា **វាទិនា** ដោយសេចក្តីថា អ្នកពោលថា ខ្ញុំសម្លាប់សាមហើយ ។

បទថា **បវាឡំ** បានដល់ត្រួយខ្ចី ។

បទថា **មាលុតេរិតំ** ដោយសេចក្តីថា ត្រូវខ្យល់បោកបក់ឱ្យញាប់ញ័រ ។

លំដាប់នោះ ទុកូលបណ្ឌិត កាលដែលនឹងប្រទានឱវាទដល់នាងបារិកាតបស្សិនីនោះ ទើបពោលថា :

**ចារិកេ កាសិរាជាយំ សោ សាមំ មិគសម្មតេ**
**កោធសា ឧសុនា វិជ្ឈិ តស្ស មា បាបមិច្ឆិម្ហា ។**

នេះកាសិករាជណាបារិកា យើងកុំប្រាថ្នានូវបាបដល់ទ្រង់
ស្តេចបានបាញ់សាមព្រោះក្រោធក្នុងអង្គ នៅត្រង់ឆ្នេរស្ទឹងមិគសម្មតា ។

បណ្តាបទទាំងនោះ បទថា **មិគសម្មតេ** ដោយសេចក្តីថា នៅឯឆ្នេរខ្សាច់មាត់ច្រាំងមិគសម្មតានទី ។

បទថា **កោធសា** មានសេចក្តីថា ដោយសេចក្តីក្រោធដែលកើតឡើងព្រោះម្រឹគទាំងឡាយ ។

បទថា **មា បាបមិច្ឆិម្ហា** ដោយសេចក្តីថា យើងទាំងពីរកុំប្រាថ្នាបាបចំពោះព្រះអង្គឡើយ ។

បារិកាតបស្សិនី ពោលទៀតថា :

**កិច្ឆា លទ្ធោ បិយោ បុត្តោ យោ អន្ធេ អភរី វនេ**
**តមេកបុត្តឃាតម្ហិ កថំ ចិត្តំ ន កោបយេ ។**

-៨១-   -៨២-

បុត្រដែលចិញ្ចឹមយើងខ្វាក់ក្នុងព្រៃ បុត្រពេញហឫទ័យរកបានដោយក្រ
ចិត្តស្ងប់នឹងអ្នកសម្លាប់បុត្រល្អ បុត្រទោលសែនក្រដូចម្ដេចបានទៅ ។

បណ្ដាបទទាំងនោះ បទថា **ឃាតម្ហិ** ប្រែថា ក្នុងបុគ្គលអ្នកសម្លាប់ ។

ទុកូលបណ្ឌិតពោលថា :

**កិច្ឆា លទ្ធោ បិយោ បុត្តោ យោ អទ្ធេ អកីរ វនេ**
**តមេកបុត្តឃាតម្ហិ អកោធំ អាហុ បណ្ឌិតា ។**

បុត្រដែលចិញ្ចឹមយើងខ្វាក់ក្នុងព្រៃ បុត្រពេញហឫទ័យរកបានដោយក្រ
ចិត្តស្ងប់មិនក្រោធបណ្ឌិតអបអរ ស្ងប់នឹងឃាតករសម្លាប់បុត្រទោល ។

បណ្ដាបទទាំងនោះ បទថា **អកោធំ** ដោយសេចក្ដីថា បណ្ឌិតទាំងឡាយ រមែងសរសើរ គឺពោលដល់បុគ្គលអ្នកមិនក្រោធនោះថា : ដែលឈ្មោះថាសេចក្ដីក្រោធ រមែងធ្វើឱ្យធ្លាក់នរក ដូច្នោះ មិនគប្បីធ្វើសេចក្ដីក្រោធនោះឡើយ គប្បីធ្វើនូវការមិនក្រោធ តែម្យ៉ាងក្នុងបុគ្គលដែលជាអ្នកសម្លាប់បុត្រនោះ ។

ក៏កាលដែលពោលយ៉ាងនេះហើយ តាបសតាបសី



ទាំងពីរក៏គក់ទ្រូងដោយដៃទាំងពីរ ពណ៌នាគុណរបស់ព្រះពោធិសត្វ យំពោលរៀបរាប់ដ៏ច្រើន ។

លំដាប់នោះ ព្រះបាទបិលយក្ខ កាលដែលនឹង លួងលោម យកចិត្តតាបសទាំងពីរនោះ ទើបត្រាស់ថា :

**មា ពាឡ្ហំ បរិទេវេថ ហតោ សាមោតិ វាទិនា**
**អហំ កម្មករោ ហុត្វា ភរិស្សាមិ ព្រហាវនេ ។**

អ្នកកុំខ្សឹកខ្សួលយំពោលខ្លាំងក្លា ព្រោះឮពាក្យថាសាមខ្ញុំសម្លាប់
ខ្ញុំនឹងចិញ្ចឹមការងារខ្ញុំរ៉ាប់ ជំនាញខ្ញុំស្រាប់នៅក្នុងព្រៃធំ ។

**ឥស្សត្ថេ ចស្មិ កុសលោ ទឡ្ហធម្មោតិ វិស្សុតោ**
**អហំ កម្មករោ ហុត្វា ភរិស្សាមិ ព្រហាវនេ ។**

ខ្ញុំអ្នកឈ្លាសវៃក្នុងសិល្បធ្នូ ឈ្មោះល្បីមកយូរទ្រង់ធ្នូដ៏មាំ
ខ្ញុំនឹងចិញ្ចឹមការងារខ្ញុំទ្រាំ ខ្ញុំខំលកលៃក្នុងព្រៃគីរី ។

**មិគានំ វិឃាសមន្វេសំ វនមូលផលានិ ច**
**អហំ កម្មករោ ហុត្វា ភរិស្សាមិ ព្រហាវនេ ។**

ខ្ញុំនឹងធ្វើការរករំពាម្រឹគ ផ្លែឈើសន្ទឹកមើមក្នុងធរណី
យកមកចិញ្ចឹមនូវលោកទាំងពីរ ក្នុងព្រៃគីរីទីឋានមហាវន័ ។

បណ្តាបទទាំងនោះ បទថា **ទានិនា** ដោយសេចក្តីថា អ្នកទាំងពីរកុំពោលពាក្យជាដើមថា បុត្រដែលដល់ព្រមដោយគុណយ៉ាងនេះរបស់យើង ត្រូវសម្លាប់ហើយឥឡូវនេះ នរណានឹងចិញ្ចឹមពួកយើង ដូច្នេះហើយក៏យំរៀបរាប់អ្វីទៅច្រើនពេកឡើយ ។ ខ្ញុំនឹងធ្វើការងារដល់អ្នកទាំងពីរ ចិញ្ចឹមបីបាច់ថែរក្សាអ្នកទាំងពីរ ដូចជាសាមដែរ ។ កាលដែលត្រាស់យ៉ាងនេះហើយ ព្រះរាជាបានលួងលោមដល់អ្នកទាំងពីរនោះថា : សូមអ្នកទាំងពីរកុំគិតអ្វីឡើយ ខ្ញុំមិនត្រូវការនូវរាជសម្បត្តិទេ ខ្ញុំនឹងចិញ្ចឹមមើលអ្នកទាំងពីររហូតដល់អស់ជីវិត ។

លំដាប់នោះ ចំណែកតាបសតាបសី បានសន្ទនាជាមួយនឹងព្រះរាជា ក្រាបទូលថា :

**នេស ធម្មោ មហារាជ នេតំ អម្ហេសុ កប្បតិ**
**រាជា ត្វមសិ អម្ហាកំ បាទេ វន្ទាម តេ មយំ។**

បពិត្រមហារាជនេះមិនមែនធម៌ ទំនៀមមិនល្អមិនសមគួរឡើយ
ព្រះអង្គជាស្តេចនៃយើងទៅហើយ ទ្រង់អើយយើងសូមបង្គំបាទា ។



បណ្តាបទទាំងនោះ បទថា **ធម្មោ** បានដល់ទំនៀមឬហេតុការណ៍ ។

បទថា **នេតំ អម្ហេសុ កប្បតិ** ដោយសេចក្តីថា ការងាររបស់ព្រះអង្គនោះ រមែងមិនគួរ គឺមិនល្អ មិនសមគួរដល់អាត្មាទាំងពីរទេ ។

បទថា **បាទេ វន្ទាម តេ** ដោយសេចក្តីថា តាបសតាបសីទាំងពីរនោះ តាំងនៅក្នុងភេទបព្វជិត ទូលព្រះរាជាដូច្នេះ ព្រោះសេចក្តីសោកក្នុងបុត្រគ្របសង្កត់ និងព្រោះមិនមានមានះ ។

ព្រះរាជាទ្រង់បានព្រះសណ្តាប់ដូច្នោះហើយ ទ្រង់ត្រេកអរដ៏ក្រៃលែង ទ្រង់គិតថា ឱ គួរអស្ចារ្យ សូម្បីត្រឹមតែពាក្យអាក្រក់របស់ឥសីទាំងពីរនេះ ក៏មិនមានចំពោះយើងដែលជាអ្នកប្រទូសរ៉ាយដ៏ខ្លាំងនេះ ត្រឡប់ជាលើកតម្កើងយើងទៀត ទើបទ្រង់ត្រាស់យ៉ាងនេះថា :

**ធម្មំ នេសាន ភណថ កតា អបចិតី តយា**
**បិតា ត្វមសិ អម្ហាកំ មាតា ត្វមសិ បារិកេ ។**

ពូជអ្នកនេសាទមានឱវាទធម៌ គារវៈបវរចិត្តល្អសុខុម
សូមលោកធ្វើជាបិតានៃខ្ញុំ បង្គំបារិកាមាតាខ្ញុំពិត ។

បណ្ដាបទទាំងនោះ បទថា **តយា** ដោយសេចក្ដីថា កាលដែលជាមនុស្សៗ ក៏ពោលយ៉ាងនេះ ។

បទថា **បិតា** ជាដើម ដោយសេចក្ដីថា បពិត្រលោកឪទុកូលបណ្ឌិត ចាប់តាំងតែពីថ្ងៃនេះទៅ សូមលោកតាំងនៅក្នុងឋានៈជាបិតារបស់ខ្ញុំ ។ បពិត្រម៉ែបារិកា សូម្បីម៉ែ ក៏ចូរតាំងនៅក្នុងឋានៈជាមាតារបស់ខ្ញុំ រីឯខ្ញុំ ក៏តាំងនៅក្នុងឋានៈជាសាមកុមារ បុត្ររបស់លោក ធ្វើកិច្ចគ្រប់យ៉ាងមានលាងបាទាជាដើម សូមលោកទាំងពីរកុំកំណត់ខ្ញុំថាជាព្រះរាជា ចូរកំណត់ថាដូចសាមកុមារចុះ ។

តាបសទាំងពីរផ្គងអញ្ជលីសំពះ កាលដែលនឹងទូលអង្វរថា សូមថ្វាយព្រះពរមហាបពិត្រ ព្រះអង្គមិនមានតួនាទីដែលនឹងត្រូវធ្វើការងារដល់អាត្មាទាំងពីរឡើយ ។ ប៉ុន្តែសូមព្រះអង្គ ទ្រង់កាន់ចុងឈើច្រត់របស់អាត្មាភាពទាំងពីរ ហើយនាំទៅឱ្យដល់កូនសាមផងចុះ ទើបពោល



ពីរគាថា :

**នមោ តេ កាសិរាជត្ថុ នមោ តេ កាសិវឌ្ឍន**
**អញ្ជលិន្តេ បគ្គណ្ហាម យាវ សាមានុបាបយ ។**
**តស្ស បាទេ សមជ្ជន្តា មុខញ្ច ភុជទស្សនំ**
**សំសុម្ភមានា អត្តានំ កាលមាគមយាមសេ ។**

ខ្ញុំសូមបង្គំអង្គព្រះរាជា ទ្រង់ព្រះវឌ្ឍនានាដែនកាសី
ទូលបង្គំប្រណម្យសូមទ្រង់ប្រណី នាំយើងឥសីដើម្បីជួបសាម ។
ទូលបង្គំទាំងពីរនឹងច្របាច់ជើង ចាប់ខ្លួនលើកឡើងស្ទាបមុខស្ទាបស្នាម
ហើយយើងនឹងត្រៀមដើម្បីស្លាប់តាម អុះឱកូនសាមមុខគួរគយគន់ ។

បណ្ដាបទទាំងនោះ បទថា **យាវ សាមានុបាបយ** ដោយសេចក្ដីថា សូមទានប្រោស នាំអាត្មាទាំងពីរ ឱ្យបានទៅដល់ទីដែលសាមកុមារនៅ ។

បទថា **ភុជទស្សនំ** ដោយសេចក្ដីថា សាមកុមារដ៏ល្អស្អាតគួរគយគន់ គឺមានរូបស្អាតគួរជ្រះថ្លា ។

បទថា **សំសុម្ភមានា** បានដល់ ច្របាច់ ។

បទថា **កាលមាគមយាមសេ** ដោយសេចក្ដីថា

នឹងធ្វើ គឺនឹងដល់នូវកាលកិរិយា ។

កាលដែលបុគ្គលទាំងបីសន្ទនាគ្នារហូតមកនេះ ព្រះអាទិត្យក៏អស្តង្គត ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា បើយើងនាំតាបសទាំងពីរ ទៅកាន់សំណាក់នៃសុវណ្ណសាមក្នុងពេលឥឡូវនេះ ហឫទ័យរបស់តាបសទាំងពីរនឹងបែកធ្លាយ ព្រោះឃើញសុវណ្ណសាមនោះ យើងក៏នឹងធ្លាក់នរក ក្នុងកាលដែលលោកទាំងបីធ្វើកាល-កិរិយា ដោយប្រការដូច្នេះឯង ព្រោះហេតុនោះ យើងនឹងមិនឱ្យតាបសតាបសីទាំងពីរនេះទៅឡើយ ទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបត្រាស់នូវគាថា ៤ គាថា :

**ព្រហាវាឡមិគាកិណ្ណំ អាកាសន្តំវ ទិស្សតិ**
**យត្ថ សាមោ ហតោ សេតិ ចន្ទោវ បតិតោ ឆមា ។**

សាមស្លាប់ហើយដេកដូចព្រះចន្ទធ្លាក់ លើផែនដីជាក់ក្នុងព្រៃស្រោងស្រុះ
សុទ្ធសត្វសាហាវនៅពេញព្រៃនោះ ព្រៃធំស្រោងស្រុះខ្ពស់កប់អាកាស ។

**ព្រហាវាឡមិគាកិណ្ណំ អាកាសន្តំវ ទិស្សតិ**
**យត្ថ សាមោ ហតោ សេតិ សុរិយោ បតិតោ ឆមា ។**



សាមស្លាប់ហើយដេកដូចសុរិយាធ្លាក់ លើផែនដីជាក់ក្នុងព្រៃដ៏ក្រាស់
សុទ្ធសត្វសាហាវច្រើនមីរដេរដាស ព្រៃខ្ពស់ខ្លាំងណាស់កប់អាកាសា ។

**ព្រហាវាឡមិគាកិណ្ណំ អាកាសន្តំវ ទិស្សតិ**
**យត្ថ សាមោ ហតោ សេតិ បំសុនា បរិកុណ្ឋិតោ ។**

សាមស្លាប់ហើយដេកប្រឡាក់អាចម៍ដី ឋិតនៅក្នុងព្រៃៗខ្ពស់អស្ចារ្យ
សុទ្ធសត្វសាហាវពេញព្រៃនោះណា កប់អាកាសាព្រៃខ្ពស់ពន្លឹក ។

**ព្រហាវាឡមិគាកិណ្ណំ អាកាសន្តំវ ទិស្សតិ**
**យត្ថ សាមោ ហតោ សេតិ ឥធេវ វសថស្សមេ ។**

សាមស្លាប់ហើយដេកនៅក្នុងព្រៃក្រាស់ ខ្ពស់កប់អាកាសពេញដោយពាឡម្រឹគ
សូមអ្នកទាំងពីរស្តាប់ហើយរលឹក គិតនឹកថានៅអាស្រមនេះហើយ ។

បណ្តាបទទាំងនោះ បទថា **ព្រហា** បានដល់ខ្ពស់ដ៏ក្រៃលែង ។

បទថា **អាកាសន្តំ** ដោយសេចក្តីថា ព្រៃនោះឯងបានដឹងគ្នាមកថា ហាក់ដូចជាដល់ទីបំផុតនៃអាកាស (ខ្ពស់កប់អាកាស) ។

បទថា **ឆមា** បានដល់លើផែនដី គឺប្រឹថពី ។ បាឋៈថា **ឆមំ** ដូច្នេះក៏មាន ដោយសេចក្តីថា ដូចធ្លាក់ចុះលើ

ផែនដី ។

បទថា **បរិក្ខណ្ឌិតោ** ដោយសេចក្ដីថា ប្រឡាក់ប្រឡូស ។

លំដាប់នោះ តាបសតាបសីទាំងពីរបានពោលគាថាដើម្បីនឹងសម្ដែងថា ខ្លួនមិនខ្លាចពាឡម្រឹគទាំងឡាយ :

**យន្តិ តត្ថ សហស្សានិ សតានិ នហុតានិ ច**
**នេវម្ហាកំ ភយំ កោចិ វនេ វាឡេសុ វិជ្ជតិ ។**

ទោះជាទីនោះមានសុទ្ធពាឡម្រឹគ រយពាន់គគ្រឹកសន្ធឹកម៉ឺនក្ដី
បន្តិចបន្តួចក៏យើងឥតភ័យ ពាឡម្រឹគក្នុងព្រៃយើងមិនភ័យឡើយ ។

បណ្ដាបទទាំងនោះ បទថា **កោចិ** ដោយសេចក្ដីថា ក្នុងព្រៃនេះ សូម្បីជាប្រទេសគឺកន្លែងណាមួយក៏ដោយ ក៏អាត្មាទាំងពីរមិនមានការភ័យខ្លាច ក្នុងពួកពាឡម្រឹគទាំងឡាយឡើយ ។

លំដាប់នោះ ព្រះរាជាកាលដែលមិនអាចហាមឥសីទាំងពីរនោះបាន ទ្រង់ក៏ដឹកដៃនាំទៅកាន់ទីដែលសុវណ្ណសាមដួលដេកនៅ ។



ព្រះបរមសាស្ដា កាលដែលទ្រង់ប្រកាសនូវសេចក្ដីនោះ ទើបត្រាស់ថា :

**តតោ អន្ធានមាទាយ កាសិរាជា ព្រហាវនេ**
**ហត្ថេ គហេត្វា បក្កាមិ យត្ថ សាមោ ហតោ អហុ ។**

គ្រានោះ ព្រះរាជាដ៏ជាធំ ក្នុងដែនកាសី ដឹកដៃនាំជនខ្វាក់ទាំងពីរ ទៅក្នុងព្រៃធំ សុវណ្ណសាមត្រូវស្លាប់ក្នុងទីណា ទ្រង់ក៏នាំទៅទីនោះ ។

បណ្ដាបទទាំងនោះ បទថា **តតោ** ប្រែថា ក្នុងកាលនោះ ។

បទថា **អន្ធានំ** បានដល់ ឥសីទាំងពីរជាមនុស្សភ្នែកងងឹត ។

បទថា **អហុ** ប្រែថា បានប្រព្រឹត្តទៅហើយ ។

បទថា **យត្ថ** ដោយសេចក្ដីថា ព្រះបាទកាសី ទ្រង់នាំឥសីទាំងពីរ ទៅក្នុងទីដែលសុវណ្ណសាមដេកនៅ ។

គ្រាកាលដែលព្រះរាជាទ្រង់នាំទៅហើយ ប្រថាប់ឈរក្នុងទីជិតសុវណ្ណសាម រួចហើយទ្រង់ត្រាស់ថា : នេះ

គឺបុត្ររបស់អ្នកជាម្ចាស់ទាំងពីរ ។ លំដាប់នោះ តាបស ដែលជាបិតារបស់ព្រះពោធិសត្វ ទ្រសីសៈព្រះពោធិសត្វ ដាក់លើភ្លៅ រីឯតបស្សិនីដែលជាមាតាក៏លើកជើងព្រះ-ពោធិសត្វដាក់លើភ្លៅរបស់ខ្លួន អង្គុយយំរៀបរាប់ ។

ព្រះបរមសាស្តា កាលដែលទ្រង់ប្រកាសនូវសេចក្តី នោះ ទើបត្រាស់នូវព្រះគាថា មានជាអាទិ៍ថា :

**ឆិស្វាន បតិតំ សាមំ    បុត្តកំ បំសុកុណ្ឋិតំ**
**អបវិទ្ធំ ព្រហារញ្ញេ    ចន្ទំវ បតិតំ ឆមា ។**

តាបសតាបសីទាំងពីរ ឃើញ (គឺដឹង) នូវសាមជា បុត្រដួលប្រឡាក់ប្រឡូសដោយធូលីដី ដែលត្រូវគេបោះ-បង់ចោលក្នុងព្រៃធំ ហាក់ដូចជាព្រះចន្ទដែលធ្លាក់មកលើ ប្រឹថពី ។

**ឆិស្វាន បតិតំ សាមំ    បុត្តកំ បំសុកុណ្ឋិតំ**
**អបវិទ្ធំ ព្រហារញ្ញេ    សុរិយំវ បតិតំ ឆមា ។**

បានឃើញ (គឺដឹង) នូវសាមជា បុត្រដួលប្រឡាក់ ប្រឡូសដោយធូលីដី ដែលត្រូវគេបោះបង់ចោលក្នុងព្រៃធំ



ដូចជាព្រះអាទិត្យដែលធ្លាក់មកលើប្រឹថពី ។

**ឆិស្វាន បតិតំ សាមំ    បុត្តកំ បំសុកុណ្ឋិតំ**
**អបវិទ្ធំ ព្រហារញ្ញេ    កលុនំ បរិទេវយុំ ។**

ឃើញ (គឺដឹង) នូវសាមជាបុត្រដួលប្រឡាក់ប្រឡូស ដោយធូលីដី ដែលត្រូវគេបោះបង់ចោលក្នុងព្រៃ ក៏យំ រៀបរាប់គួរឱ្យអាណិត ។

**ឆិស្វាន បតិតំ សាមំ    បុត្តកំ បំសុកុណ្ឋិតំ**
**ពាហា បគ្គយ្ហ បក្កន្ទុំ    អធម្មោ កិរ ភោ ឥតិ ។**

ឃើញ (គឺដឹង) នូវសាមជាបុត្រដួលប្រឡាក់ប្រឡូស ដោយធូលីដី ហើយផ្គងដើមដៃយំទង្គឹះខ្សឹកខ្សួលថា ហៃ បាដ៏ចម្រើន ការស្លាប់នេះមានសភាពមិនគួរទេ ។

**ពាឡ្ហំ ខោ ត្វំ បមត្តោសិ    សាម កល្យាណទស្សន**
**យោ អជ្ជេវង្គតេ កាលេ    ន កិញ្ចិមភិភាសសិ ។**

ឱបាសាមអើយ អ្នកមានរូបល្អគួរឱ្យគយគន់ បាឯង ជាមនុស្សស្រវឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈ ថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។

**ពាឡ្ហំ ខោ ត្វំ បធិត្តោសិ សាម កល្យាណទស្សន**
**យោ អជ្ជេវង្គតេ កាលេ ន កិញ្ចិមភិភាសសិ ។**

ឱបាសាមអើយ អ្នកមានរូបល្អគួរឱ្យគយគន់ បាឯង ជាមនុស្ស ភ្លើតភ្លើនខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ ។

**ពាឡ្ហំ ខោ ត្វំ បកុទ្ធោសិ សាម កល្យាណទស្សន**
**យោ អជ្ជេវង្គតេ កាលេ ន កិញ្ចិមភិភាសសិ ។**

ឱបាសាមអើយ អ្នកមានរូបល្អគួរឱ្យគយគន់ បាឯង ខឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើង បន្តិចបន្តួចសោះ ។

**ពាឡ្ហំ ខោ ត្វំ បសុត្តោសិ សាម កល្យាណទស្សន**
**យោ អជ្ជេវង្គតេ កាលេ ន កិញ្ចិមភិភាសសិ ។**

ឱបាសាមអើយ អ្នកមានរូបល្អគួរឱ្យគយគន់ បាឯង ដេកលក់ស៊ប់ បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើង បន្តិចបន្តួចសោះ ។

**ពាឡ្ហំ ខោ ត្វំ វិមនោសិ សាម កល្យាណទស្សន**

-៩៥-

**យោ អជ្ជេវង្គតេ កាលេ ន កិញ្ចិមភិភាសសិ ។**

ឱបាសាមអើយ អ្នកមានរូបល្អគួរឱ្យគយគន់ បាឯង ជាបុគ្គលតូចចិត្តខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ បាឯងឥតនិយាយរកយើង បន្តិចបន្តួចសោះ ។

**ជដំ វលិនំ បំសុគតំ កោទានិ សណ្ឋបេស្សតិ**
**សាមោ អយំ កាលកតោ អន្ធានំ បរិចារិកោ ។**

ឥឡូវនេះ នរណានឹងរៀបចំជដា ដ៏សៅហ្មង ប្រឡាក់ប្រឡូសដោយធូលីដី ព្រោះសាមដែលជាអ្នកបម្រើមនុស្សងងឹតយើងនេះ ធ្វើមរណកាលហើយ ។

**កោ នោ សម្មជ្ជនាទាយ សម្មជ្ជិស្សតិ អស្សមំ**
**សាមោ អយំ កាលកតោ អន្ធានំ បរិចារិកោ ។**

ឥឡូវនេះ នរណានឹងកាន់អំបោស បោសអាស្រម ដើម្បីយើង ព្រោះសាមដែលជាអ្នកបម្រើមនុស្សងងឹតយើងនេះ ធ្វើមរណកាលហើយ ។

**កោទានិ ន្ហាបយិស្សតិ សីតេនុណ្ហោទកេន ច**
**សាមោ អយំ កាលកតោ អន្ធានំ បរិចារិកោ ។**

-៩៦-

ឥឡូវនេះ នរណានឹងផ្ងូតទឹកយើង ដោយទឹកត្រជាក់ ទឹកក្តៅ ព្រោះសាមដែលជាអ្នកបម្រើមនុស្សងងឹតយើងនេះ ធ្វើមរណកាលហើយ ។

**កោទានិ តោជយិស្សតិ វនមូលផលានិ ច**
**សាមោ អយំ កាលកតោ អន្ធានំ បរិចារិកោ ។**

ឥឡូវនេះ នរណានឹងឱ្យយើងបរិភោគ មើមឈើផ្លែឈើ ព្រោះសាមដែលជាអ្នកបម្រើមនុស្សងងឹតយើងនេះ ធ្វើមរណកាលហើយ ។

បណ្តាបទទាំងនោះ បទថា **អបវិទ្ធំ** ដោយសេចក្តីថា ទុកចោលយ៉ាងអត់ប្រយោជន៍ ។

បទថា **អធម្មោ កិរ ភោ ឥតិ** ដោយសេចក្តីថា បានឮថា ភាពអយុត្តិធម៌កំពុងប្រព្រឹត្តទៅក្នុងលោកនេះក្នុងថ្ងៃនេះឯង ។

បទថា **មត្តោ** ដោយសេចក្តីថា ស្រវឹង គឺដល់នូវសេចក្តីប្រមាទ ដូចផឹកស្រាខ្លាំង ។ គឺតាបសតាបសីនិយាយរវើរវាយ ដោយប្រការផ្សេង ៗ ។



បទថា **ជដំ** បានដល់ជដារបស់យើងទាំងពីរដែលសៅហ្មង ។

បទថា **បំសុគតំ** ដោយសេចក្តីថា ប្រឡាក់ប្រឡូសដោយធូលីដីក្នុងវេលាណា ។

បទថា **កោទានិ** ដោយសេចក្តីថា ឥឡូវនេះនរណានឹងរៀបចំជដានោះឱ្យត្រង់ គឺធ្វើឱ្យស្អាត គឺធ្វើឱ្យត្រង់ក្នុងវេលានោះ ។

លំដាប់នោះ តបស្សិនីជាមាតានៃព្រះពោធិសត្វកំពុងតែយំសោករៀបរាប់ដ៏ខ្លាំងក្លានោះ បានយកដៃល្ងូកទៅស្ទាបទ្រូងរបស់ព្រះពោធិសត្វ ពិចារណានូវកម្តៅ គិតថា កម្តៅភ្លើងធាតុនៃបុត្ររបស់យើង កំពុងប្រព្រឹត្តទៅនៅឡើយ បុត្រយើងសន្លប់ដោយកម្លាំងថ្នាំពិស ដូច្នេះយើងនឹងធ្វើនូវសច្ចកិរិយាដល់បុត្ររបស់យើង ដើម្បីដកនូវពិសចេញ គិតដូច្នេះហើយ ក៏បានធ្វើនូវសច្ចកិរិយា ។

ព្រះបរមសាស្តា កាលដែលទ្រង់ប្រកាសនូវសេចក្តីនោះ ទើបត្រាស់ថា :

ទិស្វាន បតិតំ សាមំ បុត្តកំ បំសុកុណ្ឋិតំ
អដ្ដិតា បុត្តសោកេន មាតា សច្ចំ អភាសថ ។

មាតាឃើញ (គឺដឹង) ថាសាមជាបុត្រ ដួលប្រឡាក់ប្រឡូសដោយធូលីដី ត្រូវសេចក្ដីសោកចំពោះបុត្របៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា :

យេន សច្ចេនយំ សាមោ ធម្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។

ក្នុងកាលមុន សាមនេះជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

យេន សច្ចេនយំ សាមោ ព្រហ្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។

ក្នុងកាលមុន សាមនេះជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។



យេន សច្ចេនយំ សាមោ សច្ចវាទី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។

ក្នុងកាលមុន សាមនេះជាអ្នកពោលនូវពាក្យពិត (មាននូវសច្ចវាចា) ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

យេន សច្ចេនយំ សាមោ មាតាបេត្តិភរោ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។

សាមនេះ ជាអ្នកចិញ្ចឹមនូវមាតាបិតា ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

យេន សច្ចេនយំ សាមោ កុលេ ជេដ្ឋាបចាយិកោ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។

សាមនេះ ជាអ្នកប្រព្រឹត្តកោតក្រែង នូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

**យេន សច្ចេនយំ សាមោ  ធារណា  បិយតរោ  មម**
**ឯតេន សច្ចវជ្ជេន       វិសំ សាមស្ស ហញ្ញតុ ។**

សាមនេះជាទីស្រឡាញ់ ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

**យំ កិញ្ចិត្ថិ កតំ បុញ្ញំ   មយ្ហញ្ចេវ បិតុច្ច តេ**
**សព្វេន តេន កុសលេន   វិសំ សាមស្ស ហញ្ញតុ ។**

បុណ្យឯណានីមួយ ដែលខ្ញុំផង ដែលបិតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឱ្យពិសរបស់សាម សាបរលាបទៅ ។

បណ្ដាបទទាំងនោះ បទថា **យេន សច្ចេន** បានដល់ ដោយសេចក្ដីពិតណា គឺដោយសភាវៈណា ។

បទថា **ធម្មចារី** បានដល់ អ្នកប្រព្រឹត្តធម៌គឺកុសលកម្មបថ ១០ ។

បទថា **សច្ចវាទី** ដោយសេចក្ដីថា មិនពោលមុសាវាទ សូម្បីដោយការសើចលេង ។



បទថា **មាតាបេត្តិភរោ** ដោយសេចក្ដីថា ជាអ្នកមិនខ្ជិល ចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាទាំងយប់ទាំងថ្ងៃ។

បទថា **កុលេ ជេដ្ឋាបចាយិកោ** ដោយសេចក្ដីថា ជាអ្នកធ្វើនូវសក្ការបូជា ដល់បិតាជាដើម ដែលជាអ្នកចម្រើនជាទីបំផុត ។

កាលមាតាធ្វើនូវសច្ចកិរិយាទាំងអស់ ៧ គាថាយ៉ាងនេះហើយ សាមបណ្ឌិតក៏ប្រែខ្លួនត្រឡប់ ហើយស្ងៀមឈឹងទៅទៀតទៅ ។ លំដាប់នោះ បិតាគិតថា កូនរបស់យើង នៅមានជីវិត យើងនឹងធ្វើសច្ចកិរិយាខ្លះ ទើបបានធ្វើសច្ចកិរិយាយ៉ាងនោះ ។

ព្រះបរមសាស្ដា កាលដែលព្រះអង្គទ្រង់ប្រកាសនូវសេចក្ដីនោះ ទើបត្រាស់ថា :

**និស្វាន បតិតំ សាមំ   បុត្តកំ បំសុកុណ្ឋិតំ**
**អដ្ដិតោ បុត្តសោកេន   បិតា សច្ចំ អភាសថ ។**

បិតាឃើញ (គឺដឹង) ថាសាមជាបុត្រ ដួលប្រឡាក់ប្រឡូសដោយធូលីដី ត្រូវសេចក្ដីសោកចំពោះបុត្របៀត-

បៀនហើយ បានពោលនូវពាក្យសច្ចៈថា :

**យេន សច្ចេនយំ សាមោ ធម្មចារី បុរេ អហុ**
**ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។**

ក្នុងកាលមុន សាមនេះជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

**យេន សច្ចេនយំ សាមោ ព្រហ្មចារី បុរេ អហុ**
**ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។**

ក្នុងកាលមុន សាមនេះជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

**យេន សច្ចេនយំ សាមោ សច្ចវាទី បុរេ អហុ**
**ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។**

ក្នុងកាលមុន សាមនេះជាអ្នកពោលនូវពាក្យពិត (មាននូវសច្ចវាចា) ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។



**យេន សច្ចេនយំ សាមោ មាតាបេត្តិភរោ អហុ**
**ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។**

សាមនេះ ជាអ្នកចិញ្ចឹមនូវមាតាបិតា ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

**យេន សច្ចេនយំ សាមោ កុលេ ជេដ្ឋាបចាយិកោ**
**ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។**

សាមនេះ ជាអ្នកប្រព្រឹត្តកោតក្រែង នូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

**យេន សច្ចេនយំ សាមោ បាណា បិយតរោ មម**
**ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។**

សាមនេះជាទីស្រឡាញ់ ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឱ្យពិសរបស់សាម សាបរលាបទៅ ដោយការពោលនូវពាក្យសច្ចៈនោះ ។

**យំ កិញ្ចិត្ថិ កតំ បុញ្ញំ មយ្ហញ្ចេវ មាតុច្ច តេ**

**សព្វេន តេន កុសលេន  វិសំ សាមស្ស ហញ្ញតុ ។**

បុណ្យឯណានីមួយ ដែលខ្ញុំផង ដែលមាតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឱ្យពិសរបស់សាម សាបរលាបទៅ ។

កាលដែលបិតាធ្វើសច្ចកិរិយាយ៉ាងនេះ ព្រះពោធិសត្វ ក៏ប្រែខ្លួនត្រឡប់មកម្ខាងវិញទៀត ហើយក៏ស្ងៀមឈឹងដូចមុនដែរ ។

លំដាប់នោះ ទេពធីតា ព្រះនាម **ពសុន្ធរី** បានធ្វើនូវសច្ចកិរិយា លំដាប់ទី ៣ ដល់ព្រះមហាសត្វដែរ ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់ប្រកាសនូវសេចក្តីនោះ ទើបត្រាស់ថា :

**សា ទេវតា អន្តរហិតា  បព្វតេ គន្ធមាទនេ**
**សាមស្ស អនុកម្បាយ  ឥមំ សច្ចំ អភាសថ ។**

ទេវតានោះ បាត់អំពីភ្នំគន្ធមាទន៍ បានពោលនូវពាក្យសច្ចៈនេះ ដោយសេចក្តីអនុគ្រោះដល់សាមថា :

**បព្វត្យាហំ គន្ធមាទនេ  ចិរំ រត្តំ និវាសិនី**



**ន មេ បិយតរោ កោចិ  អញ្ញោ សាមេន វិជ្ជតិ**
**ឯតេន សច្ចវជ្ជេន  វិសំ សាមញ្ញស្ស ហញ្ញតុ។**

ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍ អស់កាលជាយូរអង្វែងហើយ ឥតមាននរណាដទៃ ដែលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងសាមទេ ដោយការពោលនូវពាក្យសច្ចៈនោះ សូមឱ្យពិសរបស់សាម សាបរលាបទៅ។

**សព្វេ វនា គន្ធមយា  បព្វតេ គន្ធមាទនេ**
**ឯតេន សច្ចេវជ្ជេន  វិសំ សាមស្ស ហញ្ញតុ។**

នៅភ្នំគន្ធមាទន៍ ព្រៃព្រឹក្សាទាំងឡាយ សុទ្ធសឹងមានក្លិនក្រអូប ដោយការពោលនូវពាក្យសច្ចៈនោះ សូមឱ្យពិសរបស់សាម សាបរលាបទៅ។

បណ្តាបទទាំងនោះ បទថា **បព្វត្យាហំ** កាត់បទជា **បព្វតេ អហំ** ដោយសេចក្តីថា ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍ ។

បទថា **គន្ធមយា** បានដល់ សុទ្ធហើយទៅដោយដើមឈើដែលមានក្លិនក្រអូប ។ នៅនឹងភ្នំនោះ មិនមាន

ដើមឈើអ្វី ដែលមិនមានក្លិនក្រអូបឡើយ ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ជាបន្តទៀតថា :

**តេសំ លាលប្បមានានំ ពហុំ ការុញ្ញសញ្ហិតំ**
**ខិប្បំ សាមោ សមុដ្ឋាសិ យុវា កល្យាណទស្សនោ។**

កាលបើជនទាំងនោះ កំពុងចរចារៀបរាប់នូវពាក្យ ប្រកបដោយសេចក្តីករុណា មានប្រមាណច្រើន សាមជាមនុស្សកំលោះ មានរូបល្អ គួរឱ្យគយគន់ ក៏ក្រោកឡើងភ្លាម ។

ក្នុងបណ្តាបទទាំងនោះ បទថា **តេសំ** ដោយសេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលដែលឥសីទាំងពីរនោះ ពោលរៀបរាប់ ជារឿយៗ នោះឯង សាមបណ្ឌិតបានក្រោកឡើងយ៉ាងលឿន ។ ក្នុងកាលដែលទេពធីតាធ្វើសច្ចកិរិយា ចប់ហើយ ការឈឺចុកចាប់របស់សាមបណ្ឌិតនោះ បានវិនាសបាត់អស់ទៅ ដូចទឹកធ្លាក់ចេញពីស្លឹកឈូកដូច្នោះឯង ទាំងដែលមិនប្រាកដស្នាមរបួសដែលត្រូវបាញ់ថា បាញ់ត្រូវត្រង់នេះ ឬត្រង់ណានោះឡើយ ។



សេចក្តីអស្ចារ្យទាំងពួងគឺ ព្រះពោធិសត្វវិនាសបាត់នូវរោគ តាបសតាបសីដែលជាមាតាបិតាបានភ្នែកភ្លឺត្រឡប់មកជាប្រក្រតីវិញ ពន្លឺព្រះសុរិយាក៏ប្រាកដឡើង និងអ្នកទាំង ៤ នោះ ក៏បានប្រាកដនៅនឹងទីអាស្រមបាន ក្នុងខណៈជាមួយគ្នាតែម្តង ។ មាតាបិតាមានភ្នែកល្អជាប្រក្រតីវិញហើយ ក៏ត្រេកអរដ៏ក្រៃលែងថា : កូនសាមវិនាសបាត់នូវរោគហើយ ។ លំដាប់នោះ សាមបណ្ឌិតបានពោលដល់អ្នកទាំងនោះ ដោយគាថាថា :

**សាមោហមស្មិ ភទ្ទំ វោ សោត្ថិនាម្ហិ សមុដ្ឋិតោ**
**មា ពាឡ្ហំ បរិទេវេថ មញ្ជុនាភិវទេថ មំ ។**

ខ្ញុំឈ្មោះសាម សេចក្តីចម្រើនចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងហើយដោយសួស្តី សូមលោកទាំងឡាយកុំខ្សឹកខ្សួលខ្លាំងឡើយ សូមលោកទាំងឡាយចរចាចំពោះខ្ញុំ ដោយពាក្យពីរោះ ។

លំដាប់នោះ ព្រះពោធិសត្វបែរទៅព្រះរាជា កាលដែលនឹងទូលបដិសណ្ឋារៈ ទើបពោលគាថាទាំងនេះថា :

**ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ**
**ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។**

បពិត្រមហារាជ ព្រះរាជដំណើររបស់ព្រះអង្គមកល្អហើយ ទ្រង់យាងមកមិនអាក្រក់ទេ ព្រះអង្គជាធំទ្រង់យាងមកដល់ហើយ វត្ថុណាមាននៅក្នុងទីនេះ សូមព្រះអង្គទ្រង់ជ្រាបចុះ ។

**តិណ្ឌុកានិ បិយាលានិ មធុកេកាសមារិយោ**
**ផលានិ ខុទ្ទកប្បានិ ភុញ្ជ រាជ វរំ វរំ ។**

បពិត្រមហារាជ ផលាផល មានផ្លែទន្លាប់ មាក់ប៉ែនស្រគំ សឹងមានរសផ្អែមដូចទឹកឃ្មុំ ទូលបង្គំជាខ្ញុំប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផលដែលមានរសឆ្ងាញ់ ៗ ។

**អត្ថិ មេ បានិយំ សីតំ អាភតំ គិរិគព្ភរា**
**តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ ។**

បពិត្រមហារាជ ទឹកសម្រាប់សោយដ៏ត្រជាក់ ទូលព្រះបង្គំជាខ្ញុំបាននាំមកអំពីជ្រោះភ្នំ ប្រសិនបើព្រះអង្គមាន



សេចក្តីត្រូវការ សូមទ្រង់ដងអំពីនោះ សោយចុះ ។

ចំណែកព្រះរាជាទតព្រះនេត្រឃើញអស្ចារ្យដូច្នោះទើបត្រាស់ថា :

**សម្មុយ្ហាមិ បមុយ្ហាមិ សព្វា មុយ្ហន្តិ មេ ទិសា**
**បេតន្តំ សាមមទ្ទក្ខឹ កោ នុ ត្វំ សាម ជីវសិ ។**

ខ្ញុំវង្វេងភាន់ភាំងស្មារតី ងងឹតងងល់ សព្វទិសានុទិស ព្រោះបានឃើញសាមនោះធ្វើមរណកាលហើយ ម្នាលសាម អ្នកដូចម្តេច ក៏រស់ឡើងវិញ ។

បណ្តាបទទាំងនោះ បទថា **បេតំ** ដោយសេចក្តីថា បានឃើញសាមបណ្ឌិត ធ្វើកាលកិរិយាហើយ ។

បទថា **កោ នុ ត្វំ** ដោយសេចក្តីថា ព្រះរាជាត្រាស់សួរថា អ្នកត្រឡប់រស់ឡើងវិញ បានដូចម្តេចហ្ន៎ ។

ចំណែកសាមបណ្ឌិតគិតថា ព្រះរាជាទ្រង់កំណត់យើង ថាស្លាប់ហើយ យើងនឹងប្រកាសសេចក្តីដែលយើងនៅមិនទាន់ស្លាប់ ដល់ព្រះអង្គ ទើបទូលថា :

**អបិ ជីវំ មហារាជ បុរិសំ គាឡ្ហវេទនំ**

**ឧបនីតមនសង្កប្បំ   ជីវន្តំ មញ្ញតេ មតំ ។**

បពិត្រមហារាជ សត្វលោកតែងសំគាល់នូវបុរស ដែលមានវេទនាធ្ងន់ តែនៅរស់ ឬមានសេចក្តីត្រិះរិះនៃចិត្តធ្លាក់ចុះកាន់ភវង្គ ដែលនៅរស់ ថាស្លាប់ហើយ ។

**អបិ ជីវំ មហារាជ   បុរិសំ គាឡ្ហវេទនំ**
**តំ និរោធគតំ សន្តំ   ជីវន្តំ មញ្ញតេ មតំ ។**

បពិត្រមហារាជ ម្យ៉ាងទៀត សត្វលោក តែងសំគាល់នូវបុរសដែលមានវេទនាធ្ងន់ដល់នូវការរលត់ឈឹងស្ងប់ស្ងៀម ប៉ុន្តែនៅរស់ ថាស្លាប់ហើយ ។

បណ្តាបទទាំងនោះ បទថា **អបិ ជីវំ** បានដល់ នៅរស់ពិត ៗ ។

បទថា **ឧបនីតមនសង្កប្បំ** បានដល់ មានវារចិត្តធ្លាក់ចុះកាន់ភវង្គ ។

បទថា **ជីវន្តំ** ប្រែថា នៅមានជីវិតរស់ពិត ៗ ។

បទថា **មញ្ញតេ** ដោយសេចក្តីថា លោកនេះរមែងសំគាល់ថា បុគ្គលនេះ ស្លាប់ហើយ ។



បទថា **និរោធគតំ** ដោយសេចក្តីថា សាមបណ្ឌិតពោលថា លោករមែងសំគាល់បុគ្គលដែលមានជីវិត មានអស្សាសប្បស្សាសៈដល់នូវការរលត់ រម្ងាប់ហើយ ដូចជាខ្ញុំនេះឯង ថាស្លាប់ហើយ យ៉ាងនេះ ។

ក៏កាលដែលទូលយ៉ាងនេះហើយ ព្រះពោធិសត្វបំណងនឹងប្រកបព្រះរាជាទុកក្នុងប្រយោជន៍ បានពោលនូវព្រះគាថា ២ គាថា សម្តែងនូវព្រះធម៌ :

**យោ មាតរំ បិតរំ វា   មច្ចោ ធម្មេន បោសតិ**
**ទេវាបិ នំ តិកិច្ឆន្តិ   មាតាបេតិភរំ នរំ ។**

បុគ្គលណា តែងចិញ្ចឹមនូវមាតា និងបិតា ប្រកបដោយធម៌ ទេវតាទាំងឡាយ តែងរក្សានូវបុគ្គលអ្នកចិញ្ចឹមនូវមាតាបិតានោះ ។

**យោ មាតរំ បិតរំ វា   មច្ចោ ធម្មេន បោសតិ**
**ឥធេវ នំ បសំសន្តិ   បេច្ច សគ្គេ បមោទតិ ។**

បុគ្គលណា តែងចិញ្ចឹមនូវមាតា និងបិតា ប្រកបដោយធម៌ បណ្ឌិតទាំងឡាយក្នុងលោកនេះឯង តែង

សរសើរនូវបុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងស្ថានសួគ៌ ។

ព្រះរាជា បានស្តាប់នូវពាក្យនោះហើយ ទ្រង់ព្រះតម្រិះថា គួរអស្ចារ្យណាស់ហ្ន៎ សូម្បីទេវតាទាំងឡាយ ក៏មកព្យាបាលរោគ ដែលកើតឡើងដល់បុគ្គលអ្នកចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាដែរ សាមបណ្ឌិតនោះ ប្រសើររុងរឿងដ៏ក្រៃលែង ។ ទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ផ្គងអញ្ជលីត្រាស់ថា :

**ឯស ភិយ្យោ បមុយ្ហាមិ សព្វា មុយ្ហន្តិ មេ ទិសា**
**សរណំ សាម គច្ឆាមិ ត្វញ្ច មេ សរណំ ភវ ។**

ខ្ញុំវង្វេងដ៏ក្រៃលែង ភាន់ភាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ម្នាលសាម ខ្ញុំសូមយកអ្នកជាទីពឹងទីរលឹករបស់ខ្ញុំ ។

បណ្តាបទទាំងនោះ បទថា **ភិយ្យោ** ដោយសេចក្តីថា ព្រោះបានធ្វើខុស ដល់សាម ដែលជាបុគ្គលអ្នកមានសីលបរិសុទ្ធ សម្បូណ៌ដោយគុណធម៌ ដូច្នោះ ខ្ញុំទើបវង្វេងដ៏ក្រៃលែង ។



បទថា **ត្វញ្ច មេ សរណំ ភវ** ដោយសេចក្តីថា ខ្ញុំសូមដល់អ្នកជាសរណៈ និងសូមអ្នកជាសរណៈគឺចូរជាទីពឹងរបស់ខ្ញុំឱ្យបានទៅកាន់ទេវលោក ។

លំដាប់នោះ ព្រះពោធិសត្វបានទូលព្រះរាជាថា : បពិត្រមហារាជ បើព្រះអង្គមានព្រះបំណងទៅកាន់ទេវ-លោក មានព្រះបំណងបរិភោគនូវទិព្វសម្បត្តិដ៏ធំ ចូរទ្រង់ប្រព្រឹត្តក្នុងទសពិធរាជធម៌ចុះ កាលដែលនឹងថ្វាយឱវាទដល់ព្រះរាជា ទើបបានពោលនូវគាថា ដែលប្រកបដោយទសពិធរាជធម៌ថា :

**ធម្មញ្ចរ មហារាជ មាតាបិតូសុ ខត្តិយ**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចំពោះមាតានិងបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ បុត្តទារេសុ ខត្តិយ**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចំពោះបុត្រនិងភរិយា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ មិត្តាមច្ចេសុ ខត្តិយ**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចំពោះមិត្តនិងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ វាហនេសុ ពលេសុ ច**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចំពោះសត្វពាហនៈនិងពល បពិត្រព្រះរាជា លុះព្រះអង្គ



បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ គាមេសុ និគមេសុ ច**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចំពោះស្រុកនិងនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ រដ្ឋេសុ ជនបទេសុ ច**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ចំពោះអ្នកដែននិងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ សមណេសុ ព្រាហ្មណេសុ ច**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ចំពោះសមណៈនិងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ មិគបក្ខីសុ ខត្តិយ**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ចំពោះម្រឹគនិងបក្សីទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។

**ធម្មំ ចរ មហារាជ ធម្មោ ចិណ្ណោ សុខាវហោ**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ចំពោះធម៌ដែលប្រព្រឹត្តហើយ តែងនាំមកនូវសុខ បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ស្ថានសួគ៌ ។



**ធម្មំ ចរ មហារាជ សឥន្ទា ទេវា សព្រហ្មកា**
**សុចិណ្ណេន ទិវំ បត្តា មា ធម្មំ រាជ បាមទោ។**

បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រព្រឹត្តធម៌ ព្រោះទេវតាឥន្ទព្រហ្ម ដែលបានដល់នូវទិព្វស្ថាន ក៏ព្រោះធម៌ដែលខ្លួនបានប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ ។

ព្រះពោធិសត្វ សម្តែងធម៌ថ្វាយព្រះរាជាយ៉ាងនេះហើយ កាលដែលនឹងថ្វាយឱវាទ ឱ្យក្រៃលែងឡើង បានថ្វាយបញ្ចសីលដល់ព្រះរាជាទៀត ។ ព្រះរាជាទ្រង់ទទួលឱវាទ របស់ព្រះពោធិសត្វនោះ ដោយព្រះសិរសា ទ្រង់សំពះសូមខមាទោសព្រះពោធិសត្វ ហើយស្តេចទ្រង់ត្រឡប់ទៅក្រុងពារាណសី ។

ព្រះរាជាទ្រង់បំពេញនូវព្រះរាជកុសល មានទានជាដើម ទ្រង់រក្សានូវបញ្ចសីល គ្រងរាជសម្បត្តិស្មោះស្មើប្រកបដោយធម៌ ។ ក្នុងទីបំផុតនៃព្រះជន្ម ក៏បាននូវស្ថានសួគ៌ក្នុងលោកជាបន្ទាប់ ។ ចំណែកព្រះពោធិសត្វ បដិបត្តិ

ទំនុកបម្រុងនូវមាតាបិតា ញ៉ាំងអភិញ្ញានិងសមាបត្តិឱ្យកើតឡើង ព្រមដោយមាតានិងបិតា មិនបានសាបសូន្យចាកឈាន ក្នុងទីបំផុតនៃអាយុ ក៏ចូលដល់ព្រហ្មលោកទាំងមាតានិងបិតានោះឯង ។

ព្រះបរមសាស្ដា ទ្រង់នាំនូវព្រះធម៌ទេសនានេះមកហើយ ព្រះអង្គទ្រង់ត្រាស់ជាបន្តថា ៖ ម្នាលភិក្ខុទាំងឡាយ ការចិញ្ចឹមបីបាច់ថែរក្សានូវមាតាបិតា ជាវង្សរបស់បណ្ឌិតទាំងឡាយ ។ ព្រះអង្គត្រាស់ដូច្នេះហើយ ទ្រង់ប្រកាសអរិយសច្ចទាំងឡាយ ៤ កាលដែលចប់ស្រេចហើយ ភិក្ខុដែលចិញ្ចឹមនូវមាតាបិតានោះឯង ក៏បានសម្រេចសោតាបត្តិផល ។

ព្រះរាជា **បិលយក្ខ** ក្នុងកាលនោះត្រឡប់ជាតិមកគឺភិក្ខុឈ្មោះ **អានន្ទ** ក្នុងកាលនេះ ; **ពសុន្ធរីទេពធីតា** ជាភិក្ខុនីឈ្មោះ **ឧប្បលវណ្ណា** ; **ស្ដេចទេវរាជ** ជាភិក្ខុឈ្មោះ **អនុរុទ្ធ** ; **ទុកូលបណ្ឌិត** ដែលជាបិតា បានមកជាភិក្ខុឈ្មោះ



**មហាកស្សបៈ** ; នាង**បារិកា** ដែលជាមាតា បានមកជាភិក្ខុនីឈ្មោះ **ភទ្ទកាបិលានី** ; រីឯ **សុវណ្ណសាមបណ្ឌិត** គឺ **តថាគត** ដែលជាអរហន្តសម្មាសម្ពុទ្ធនេះឯង ។

**ចប់សុវណ្ណសាមជាតក ដែលប្រដាប់ដោយ**

**គាថា ១២៦ គាថា**

**សូមអនុមោទនា !**

ចប់

## រៀបរៀងកំណាព្យក្នុងសុវណ្ណសាមជាតក

នរណាហ្នំបាញ់ខ្ញុំជាអ្នកដងទឹក ដែលកំពុងភ្លឹកសតិបង់បាត់
ជាព្រាហ្មណ៍វៃស្សៈឬក៏ជាក្សត្រ នរណាពួនស្កាត់បាញ់ខ្ញុំដោយសរ ។
សាច់ខ្ញុំមិនមែនជាម្ហូបអាហារ ស្បែកខ្ញុំនេះណាឥតការបរវរ
ហេតុអ្វីខ្ញុំនេះត្រូវបាញ់ដោយសរ សំគាល់ថាល្អបិតនៅត្រង់ណា ។
ឱសម្លាញ់អើយខ្ញុំសូមសួរអ្នក បាញ់ខ្ញុំហើយលាក់បំពួនអាត្មា
តើអ្នកជាអ្វីជាបុត្រអ្នកណា ខ្ញុំដឹងហេតុការណ៍បានដូចម្តេចទៅ ។

ពោលគាថាហើយព្រះពោធិសត្វ អត់ទ្រាំស្ងៀមស្ងាត់ទាំងដេកដួលនៅ
ក្នុងថ្លុកឈាមឯងវេទនាផ្សាក្តៅ ស្តេចយាងសំដៅទៅតបសម្តី ។
គេស្គាល់ឈ្មោះខ្ញុំថាបិលយក្ខ ជាស្តេចនៃអ្នកក្នុងដែនកាសី
